ព្រះរាជាណាចក្រកម្ពុជា

# ការវាយបកប្រឆាំងនឹងការចោទប្រកាន់របស់ប្រទេសថៃ
# ទៅលើអង្គការយូណេស្កូ
# និងគណៈកម្មាធិការបេតិកភណ្ឌពិភពលោក

បោះពុម្ពដោយ
គណៈកម្មការជាតិកម្ពុជា
ប្រចាំយូណេស្កូ

ភ្នំពេញ
២០១០

*Christchurch, N.Z 2007*
ក្រៃឆឺច, ណូវែលហ្សេឡង់, ២០០៧

*Quebec, Canada 2008*
កេបិច, កាណាដា, ២០០៨

*Seville, Espagne 2009*
សេវីល, អែស្ប៉ាញ, ២០០៩

ព្រះរាជាណាចក្រកម្ពុជា

# ការវាយបកប្រឆាំងនឹងការចោទប្រកាន់របស់ប្រទេសថៃ
# ទៅលើអង្គការយូណេស្កូ
# និងគណៈកម្មាធិការបេតិកភណ្ឌពិភពលោក

# មាតិកា

ទំព័រ


១-ពេលវេលាដ៏សប្បាយរីករាយត្រូវបានធ្វើឱ្យអាប់អួរដោយអរិភាពរបស់ប្រទេសថៃ........១-៧
២-រវាងកម្ពុជានិងថៃ មានខ្សែបន្ទាត់ព្រំដែនអន្តរជាតិច្បាស់លាស់........ ៨-១០
៣-ប្រាសាទព្រះវិហារ, ឆ្នាំ១៩៦២ : ឆ្នាំនៃការសម្រេចចិត្ត........១១-១២
៤-គោលនយោបាយឈ្លានពានពីររបស់ថៃ ទាក់ទងនឹងប្រាសាទព្រះវិហារ........១៣-១៧
៥-ទ័ពប្រទេសថៃទន្ទ្រានកម្ពុជា ........១៨-២០
៦-ផលវិបាកនៃអរិភាពរបស់ថៃមកលើកម្ពុជា : ជម្លោះក្រោយការទន្ទ្រានទឹកដី និង ការកាន់កាប់ខុសច្បាប់........ ២១-២២
៧-អនាគតនៃប្រាសាទព្រះវិហារ........២៣
៨-ឧបសម្ព័ន្ធ:
ឧបសម្ព័ន្ធទី ១........i-iii
ឧបសម្ព័ន្ធទី ២........ iv-viii
ឧបសម្ព័ន្ធទី ៣........ix-x
ឧបសម្ព័ន្ធទី ៤........xi-xii
ឧបសម្ព័ន្ធទី ៥........ xiii-xv
ឧបសម្ព័ន្ធទី ៦........ xvi-xix
ឧបសម្ព័ន្ធទី ៧........ xx-xxi
ឧបសម្ព័ន្ធទី ៨........xxii-xxiii
ឧបសម្ព័ន្ធទី ៩........ xxiv-xxv
ឧបសម្ព័ន្ធទី ១០........ xxvi-xxvii
ឧបសម្ព័ន្ធទី ១១........xxviii-xxix

## ១. ពេលវេលាដ៏សប្បាយរីករាយត្រូវបានធ្វើឱ្យអាប់អួរដោយអរិភាពរបស់ប្រទេសថៃ

រូបភាព យូណេស្កូ

ជារៀងរាល់ឆ្នាំ ប្រតិភូនៃបណ្ដាប្រទេសជុំវិញពិភពលោកតែងមកជួបជុំគ្នាក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក (WHC) ដែលជាអង្គការមួយរបស់យូណេស្កូ (UNESCO) ឧទ្ទិសដល់ការអភិរក្សនិងការអភិវឌ្ឍប្រកបដោយចីរភាពនូវសម្បត្តិបេតិកភណ្ឌធម្មជាតិ និងសម្បត្តិបេតិកភណ្ឌមនុស្សជាតិ ដែលមានលក្ខណៈគួរឱ្យកត់សម្គាល់ និងគួរឱ្យស្ញប់ស្ញែងនៅក្នុងពិភពលោក ។ នោះគឺជាឱកាសដ៏សប្បាយរីករាយមួយ ដែលប្រទេសនានាសម្រេចដាក់ទ្រព្យសម្បត្តិដ៏មានតម្លៃរបស់ប្រជាជាតិគេចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ។

**សេចក្ដីសម្រេច : 32 COM 8B. 102**

ចុះប្រាសាទព្រះវិហាររបស់ប្រទេសកម្ពុជាទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកក្រោមលក្ខណៈវិនិច្ឆ័យ (i)

**លក្ខណៈវិនិច្ឆ័យ** (i) **:** ប្រាសាទព្រះវិហារ គឺជាស្នាដៃឯកដ៏ល្បីល្បាញរបស់ស្ថាបត្យកម្មខ្មែរ ។ គឺជា "ភាពល្អឥតខ្ចោះ" ទាំងគម្រោង ទាំងការរចនា ។

ដោយឡែក កាលពីខែកក្កដា ឆ្នាំ២០០៨ នៅពេលដែលកិច្ចប្រជុំរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោកបានប្រារព្ធឡើងនៅទីក្រុង **កេបិច** (Quebec) ប្រទេស **កាណាដា** អង្គប្រជុំបានសម្រេចជាឯកច្ឆន្ទដាក់បញ្ចូល **ប្រាសាទព្រះវិហារ** ដែលជាស្ថាបត្យកម្មរបស់ខ្មែរបានកសាងនៅសម័យអង្គរ ស្ថិតនៅចុងភាគខាងត្បូងនៃថ្ពលយ មានកម្ពស់៦២៥ម៉ែត្រ លើជួរភ្នំ "ដងរែក" ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកដែលមាន **តម្លៃជាសាកល** ក្រោមសេចក្ដីសម្រេច 32 COM 8B. 102 ទោះបីជាមានការជំទាស់យ៉ាងខ្លាំងក្លាពីភាគីថៃ ដើម្បីងាកចេញពីការសម្រេចដ៏ត្រឹមត្រូវនេះ យ៉ាងណាក៏ដោយ ។

ប្រាសាទព្រះវិហារ ជាស្នាដៃឯកមួយនៃស្ថាបត្យកម្មខ្មែរត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅថ្ងៃ ០៧ ខែកក្កដា ឆ្នាំ២០០៨។

ប្រាសាទនេះមានប្លង់អ័ក្សជើង-ត្បូង ប្រវែង៨០០ម៉ែត្រ ជាមួយនឹង "គោបុរៈ និងផ្លូវក្រាលថ្ម" ជាបន្តបន្ទាប់ ទៅរកទីសក្ការបូជាចម្បងឬគោបុរៈទី១ នៅចុងចំណោតខាងត្បូង។

គោបុរៈទី៥ ទៅចុងខាង ជើង មើលឃើញជណ្ដើរ និងខ្សែបន្ទាត់ព្រំដែនជាមួយថៃ

គោបុរៈទី៤ និង គោបុរៈទី៣

គោបុរៈទី២ និង គោបុរៈទី១

ជាការសមគួរនិងឧត្តមបំផុតក្នុងការរំឭកថា រាជរដ្ឋាភិបាលថៃបានប្ដេជ្ញាគាំទ្រយ៉ាងសកម្មចំពោះការចុះបញ្ជីនេះ ដូចដែលមានភស្តុតាងតាមរយៈសេចក្ដីប្រកាសការផ្សព្វផ្សាយព័ត៌មានរួមជាច្រើន ហើយដែលមានកម្រិតខ្ពស់បំផុតនោះ គឺសេចក្ដីថ្លែងការណ៍រួមនៅថ្ងៃ១៨ ខែមិថុនា ឆ្នាំ២០០៨ ដោយមានតំណាងយូណេស្កូចូលរួមជាសាក្សី (សូមអានសេចក្ដីថ្លែងការណ៍នេះក្នុងទំព័រទី១៥)។

មាគ៌ាទៅកាន់ទីក្រុងកេបិចជាមាគ៌ាដ៏វែងនិងដ៏លំបាកមួយ។ នៅឆ្នាំ២០០១ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានចាប់ផ្តើមសំណើជាផ្លូវការដើម្បីចុះបញ្ជីប្រាសាទព្រះវិហារ។ រាជរដ្ឋាភិបាលកម្ពុជាបានចំណាយពេលអស់៦ឆ្នាំមុននឹងឯកសារគាំទ្រការចុះបញ្ជីបានត្រូវបញ្ចប់ និងបញ្ជូនទៅមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោក ដើម្បីឱ្យអង្គការយូណេស្កូយល់ព្រម ដែលជាការបើកផ្លូវសម្រាប់ការចុះទីតាំងដ៏ជាទីសក្ការៈនេះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក តាមរយៈសេចក្តីសម្រេចរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក (WHC) ដែលមានប្រទេស២១ជាសមាជិក ជ្រើសរើសក្នុងចំណោមប្រទេសសមាជិក១៨៦នៃអនុសញ្ញាស្តីពីកិច្ចការពារ បេតិកភណ្ឌវប្បធម៌និងធម្មជាតិពិភពលោក ទីក្រុងប៉ារីស ឆ្នាំ១៩៧២។

### កាលប្បវត្តិនៃការចុះឈ្មោះ

- ១០ តុលា ២០០១ : សម្តេចតេជោ **ហ៊ុន សែន** ស្នើសុំចុះបញ្ជី
- ៣០ មិថុនា ២០០៦ : បញ្ជូនសំណុំឯកសារសម្រេចទៅមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោក យូណេស្កូ ប៉ារីស
- ២៣-២៩ តុលា ២០០៦ : បេសកកម្មបច្ចេកទេសរបស់តំណាងក្រុមប្រឹក្សាអន្តរជាតិវាយតម្លៃប្រាង្គប្រាសាទ និងរមណីយដ្ឋាន ICOMOS នៅតំបន់ប្រាសាទព្រះវិហារ
- ២១ មករា ២០០៧ : យល់ព្រមលើសំណើចុះបញ្ជីដោយ ICOMOS
- ២៣ មិថុនា-២ កក្កដា ២០០៧ : កិច្ចប្រជុំលើកទី៣១ របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក នៅ គ្រៃឆឺច (Christchurch) ប្រទេសណូវែលហ្សេឡង់ (Nouvelle Zélande)

នៅពេលកម្ពុជាដាក់ប្រាសាទព្រះវិហារសម្រាប់ការចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅកិច្ចប្រជុំលើកទី៣១ របស់ WHC នៅគ្រៃឆឺច ប្រទេសណូវែលហ្សេឡង់ នោះគណៈកម្មាធិការបានឯកភាពជាគោលការណ៍ថា ប្រាសាទព្រះវិហារគួរត្រូវចុះបញ្ជី។ ទោះជាយ៉ាងណាក្តី ការចុះបញ្ជីជាផ្លូវការត្រូវពន្យាពេលមួយឆ្នាំ ខណៈដែលត្រូវរៀបចំឯកសារបន្ថែមសម្រាប់គាំទ្រការចុះប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

| បេតិកភណ្ឌពិភពលោក | 31 COM |
|---|---|

WHC-O7/31.COM/24
ប៉ារីស ៣១ កក្កដា ២០០៧
ប្រភពដើម : បារាំង/អង់គ្លេស

អត្ថបទបកប្រែក្រៅផ្លូវការ

អង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រនិងវប្បធម៌
អនុសញ្ញាស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌និងធម្មជាតិពិភពលោក
គណៈកម្មាធិការបេតិកភណ្ឌពិភពលោក
សម័យប្រជុំលើកទី៣១
គ្រៃឆឺច , ណូវែលហ្សេឡង់
២៣ មិថុនា- ២ កក្កដា ២០០៧

**សេចក្តីសម្រេច : 31 COM 8B.24**

អត្ថបទ

១. គណៈកម្មាធិការបេតិកភណ្ឌពិភពលោក បានពិនិត្យឯកសារ WHC-07/31.COM/8B និង WHC-07/31. COM/NF.8B.1,

២.បានធ្វើកំណត់ត្រានូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយប្រធានគណៈកម្មាធិការបេតិកភណ្ឌពិភពលោកដែលបានឯកភាពដោយគណៈប្រតិភូកម្ពុជានិងគណៈប្រតិភូថៃ ÷

"ភាគីកម្ពុជានិងភាគីថៃឯកភាពទាំងស្រុងថា ទីកន្លែងប្រាសាទព្រះវិហារដ៏ពិសិដ្ឋមានតម្លៃសាកលដ៏មហស្ចារ្យ នឹងត្រូវតែចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ អាស្រ័យហេតុនេះ កម្ពុជានិងថៃឯកភាពថា កម្ពុជានឹងដាក់ស្នើទីតាំងដ៏ជាទីសក្ការៈនេះសម្រាប់ការចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកជាផ្លូវការនៅសម័យប្រជុំលើកទី៣២ របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោកក្នុងឆ្នាំ២០០៨ ជាមួយនឹងការគាំទ្រពេញទំហឹងពីប្រទេសថៃ។

ភាគីទាំងពីរក៏បានឯកភាពដែរថា តំបន់នេះទាមទារឱ្យមានការយកចិត្តទុកដាក់ជាបន្ទាន់ និងត្រូវការជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុអន្តរជាតិ និងសហប្រតិបត្តការជិតស្និទ្ធ។

ភាគីទាំងពីរឯកភាពទៀតថា គឺមានសារៈសំខាន់ខ្លាំងណាស់ដែលត្រូវពង្រឹងកិច្ចការអភិរក្សនិងការគ្រប់គ្រងនៅទីតាំង ដ៏ជាទីសក្ការៈនោះ ដោយរួមទាំងការអភិវឌ្ឍគម្រោងសមស្របមួយដូចតម្រូវការនៅក្នុងកថាខណ្ឌ១០៨ ស្តីពីការណែនាំនៃកិច្ចប្រតិបត្តិការដែលនឹងធានាកិច្ចការពារសម្បត្តិនេះនៅពេលអនាគត។

អនុលោមតាមការពិគ្រោះយោបល់ជាមួយមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោក ភាគីទាំងពីរយល់បានថាជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍគម្រោងគ្រប់គ្រងនឹងមានតាមរយៈកម្មវិធីជំនួយអន្តរជាតិរបស់មជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោក។

៣.ទទួលស្គាល់ថា តំបន់ដ៏ពិសិដ្ឋនៃប្រាសាទព្រះវិហារមានសារៈសំខាន់មហិមាជាអន្តរជាតិ និងមានតម្លៃសាកលដ៏មហស្ចារ្យលើមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យ (i), (ii) និង (iv) ហើយឯកភាពជាគោលការណ៍ថា គួរត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក និងគួរកត់សម្គាល់ថា ដំណើរការសម្រាប់ការចុះបញ្ជីគឺកំពុងតែប្រព្រឹត្តទៅ។

៤.ស្នើឱ្យភាគីកម្ពុជាពង្រឹងគម្រោងអភិរក្សនិងគ្រប់គ្រងដែលមានក្នុងការអភិវឌ្ឍគម្រោងគ្រប់គ្រងដ៏សមស្របមួយដែលជួយដល់ការចុះបញ្ជីសម្បត្តិវប្បធម៌នេះដោយគណៈកម្មាធិការនៅក្នុងកិច្ចប្រជុំលើកទី៣២ របស់ខ្លួន ឆ្នាំ២០០៨។

៥.ជាងនេះទៀត ស្នើឱ្យភាគីកម្ពុជាផ្តល់ជូនដល់មជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោកនូវរបាយការណ៍រីកចម្រើនថ្មីៗ ឱ្យបានត្រឹមថ្ងៃ០១ កុម្ភៈ ២០០៨។

| សេចក្តីថ្លែងការណ៍របស់ប្រធាន<br>នៅសម័យប្រជុំលើកទី៣១ របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក<br>គ្រៃឆឺច , ណូវែលហ្សេឡង់ |
|---|
| សេចក្តីសម្រេចនេះមានន័យថា គណៈកម្មាធិការបានឯកភាពថា ទីដ៏ពិសិដ្ឋនេះសក្តិសមនឹងទទួលបានការបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក និងថាការចុះបញ្ជីជាផ្លូវការនឹងប្រព្រឹត្តទៅនៅសម័យប្រជុំលើកក្រោយ ឆ្នាំ២០០៨ ហើយខ្ញុំស្នើឱ្យបញ្ចូលកំណត់សម្គាល់របស់ខ្ញុំក្នុងរបាយការណ៍ចុងក្រោយនៃកិច្ចប្រជុំ ព្រមជាមួយគ្នានឹងសេចក្តីសម្រេចនេះ។ |



លោក Tumu Te Heuheu

ប្រធានគណៈកម្មាធិការបេតិកភណ្ឌពិភពលោក

សកម្មភាពគណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយ ឯកឧត្តម បណ្ឌិត សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅគ្រៃឆឺច ណូវែលហ្សេឡង់ ក្នុងអំឡុងកិច្ចប្រជុំលើកទី៣១ របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក , មិថុនា-កក្កដា ២០០៧ ( រូបភាព ទីស្តីការគណៈរដ្ឋមន្ត្រី-រាជរដ្ឋាភិបាលកម្ពុជា)

ដោយបានបំពេញលក្ខខណ្ឌតម្រូវដោយកិច្ចប្រជុំលើកទី៣១របស់ WHC ខែកក្កដា ឆ្នាំ២០០៧ នៅគ្រៃឆឺចរួចមក កិច្ចប្រជុំលើកទី៣២របស់ WHC នៅថ្ងៃ ៧ ខែកក្កដា ឆ្នាំ២០០៨ នាទីក្រុងកេបិច ប្រទេសកាណាដា បានសម្រេចជាឯកច្ឆន្ទចុះបញ្ជីប្រាសាទព្រះវិហារដ៏ល្បីល្បាញដែលជាតំណាង "**ស្នាដៃឯកដ៏មហស្ចារ្យរបស់ស្ថាបត្យកម្មខ្មែរ**"។

ដោយឮព័ត៌មានពីការសម្រេចរបស់ WHC ពិធីអបអរសាទរបានកើតឡើងដោយឯកឯងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ក្នុងទសវត្សថ្មីៗនេះ ប្រជាជនកម្ពុជាកម្រមានឱកាសបានទទួលស្គាល់ពីអន្តរជាតិជាវិជ្ជមានបែបនេះណាស់ ហើយប្រជាជនកម្ពុជាបានអបអរសាទរអស់ពីដួងចិត្តចំពោះព្រឹត្តិការណ៍ដ៏សំខាន់បំផុតរបស់ប្រទេសជាតិ។

មួយសប្តាហ៍ក្រោយមក នៅថ្ងៃ១៤ កក្កដា ២០០៨ ពិធីអបអរសាទរមួយត្រូវបានរៀបចំឡើងដោយសាលារាជធានីភ្នំពេញ សហការជាមួយអគ្គនាយកដ្ឋានវិទ្យុ និងទូរទស្សន៍បាយ័ននៅក្នុងពហុកីឡាដ្ឋានជាតិ ដើម្បីទទួលការអញ្ជើញមកដល់របស់គណៈប្រតិភូកម្ពុជាពីទីក្រុងកេបិច ប្រទេសកាណាដា។ ព្រឹត្តិការណ៍នេះបានពង្រឹងបន្ថែមទៀតនូវឯកភាពជាតិទាំងមូល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាដែលបានលើកតម្កើងមោទនភាពជាតិតាមរយៈការសម្រេចស្នាដៃរបស់គណៈប្រតិភូកម្ពុជា ដឹកនាំដោយ ឯកឧត្តម បណ្ឌិត **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រីដែលលោកបានក្តាប់ឱកាសនិងបង្ហាញភាពទន់ភ្លន់ អត់ធ្មត់ប្រកបដោយទេពកោសល្យនិងសេចក្តីស្នេហាជាតិរបស់លោក ហើយបានផ្តល់នូវភាពជឿជាក់ថ្មីមួយទៀត ដល់ប្រជាជាតិក្នុងការរៀបចំខ្លួនប្រឈមមុខចំពោះបញ្ហាផ្សេងៗដទៃទៀតនៅសតវត្សទី២១នេះ។

ឯកឧត្តម បណ្ឌិត **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
ថ្លែងសន្ទរកថាក្នុងពិធីអបអរសាទរថ្ងៃ១៤ កក្កដា ២០០៨ អមដំណើរដោយលោកជំទាវ **អាន្នី សុខ អាន**
និងសមាជិកគណៈប្រតិភូដទៃទៀតមកពីកិច្ចប្រជុំលើកទី៣២ របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក
នៅកេបិច , កាណាដា

អ្នកចូលរួមក្នុងពិធីបានក្រោកឈរឡើងគ្រវីទង់ជាតិ បដា បង្ហាញនូវក្តីសប្បាយរីករាយ និងអបអរស្វាគមន៍
ឯកឧត្តម បណ្ឌិត **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
និងគណៈប្រតិភូមកពីកិច្ចប្រជុំលើកទី៣២ របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក
នៅកេបិច , កាណាដា

នៅថ្ងៃបន្ទាប់ គឺ ១៥ កក្កដា ២០០៨ ដោយបំពានធម្មនុញ្ញអង្គការសហប្រជាជាតិ និងមូលដ្ឋានគតិយុត្តិអន្តរជាតិទាំងស្រុង ទាហានថៃបានឆ្លងព្រំដែនកម្ពុជាចូលមកយ៉ាងជ្រៅក្នុងទឹកដីកម្ពុជា តម្រង់មកប្រាសាទព្រះវិហារដែលទើបបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកថ្មីៗនេះ ហើយកាន់កាប់ "ទីជិតខាងក្បែរប្រាសាទលើទឹកដីកម្ពុជា" រួមទាំងវត្តកែវសិក្ខាគីរីស្វារៈ និងតំបន់ជុំវិញវត្តទៀតផង។

កងទាហានថៃបានឆ្លងព្រំដែនហើយចូលយ៉ាងជ្រៅក្នុងទឹកដីកម្ពុជា

កងទាហានថៃកាន់កាប់វត្តកែវសិក្ខាគីរីស្វារៈនិងប៉ុស្តិ៍រដ្ឋបាលស៊ីវិលកម្ពុជា (រូបភាព ៈទីស្តីការគណៈរដ្ឋមន្ត្រី-រាជរដ្ឋាភិបាលកម្ពុជា)

សំខាន់ជាងនេះទៅទៀត ទង្វើទន្ទ្រានទឹកដីនិងកាន់កាប់ទាំងងងើលរបស់ប្រទេសថៃជាការរំលោភបំពានជាក់ស្តែងលើសាលដីកាតុលាការយុត្តិធម៌អន្តរជាតិទីក្រុងឡាអេ ១៥ មិថុនា ១៩៦២ ដែលចែងថា :

**"តុលាការ,**

**ដោយបោះឆ្នោតសម្លេង ៩ ទល់ ៣ រកឃើញថា ប្រាសាទព្រះវិហារស្ថិតនៅក្នុងទឹកដីក្រោមអធិបតេយ្យរបស់កម្ពុជា។**

**ដោយបោះឆ្នោតសម្លេង ៩ ទល់ ៣ ថា ប្រទេសថៃមានកាតព្វកិច្ចដកវាល់កម្លាំងនគរបាល ឬទាហាន ឬឆ្មាំ ឬអ្នកថែរក្សាដទៃទៀត ដែលបោះទីតាំងនៅប្រាសាទព្រះវិហារ ឬនៅទីជិតខាងក្បែរប្រាសាទ ក្នុងទឹកដីកម្ពុជា ។**

**ដោយបោះឆ្នោតសម្លេង ៧ ទល់ ៥ ថា ប្រទេសថៃមានកាតព្វកិច្ចប្រគល់សងមកឱ្យកម្ពុជាវិញនូវរាល់វត្ថុបូរាណគ្រប់ប្រភេទដែលបានបញ្ជាក់ក្នុងឯកសារស្នើទី៥របស់កម្ពុជា ដែលអាចត្រូវបានយកចេញពីប្រាសាទ ឬតំបន់ប្រាសាទដោយអាជ្ញាធរថៃ ចាប់តាំងពីថ្ងៃកាន់កាប់ប្រាសាទដោយប្រទេសថៃ ឆ្នាំ១៩៥៤ មក" ។**

សង្គ្រាមមិនមែនជារឿងចម្លែកឡើយ ព្រោះប្រជាជនកម្ពុជាធ្លាប់បានឆ្លងកាត់ជម្លោះប្រដាប់អាវុធជាច្រើនទសវត្សមកហើយ។ ប៉ុន្តែកម្ពុជាមានការភ្ញាក់ផ្អើលនិងខកចិត្តនឹងអ្វីដែលថៃបានប្រតិកម្មចំពោះព្រឹត្តិការណ៍នៃសេចក្តីសម្រេចថ្ងៃ ៧ ខែកក្កដា ឆ្នាំ២០០៨ នៅទីក្រុងកេបិច។ ការប្រើកម្លាំងយោធាដោយឥតវិចារណញ្ញាណរបស់រាជរដ្ឋាភិបាលថៃ ដើម្បីបង្ហាញអាកប្បកិរិយាជំទាស់ចំពោះបរាជ័យនៅក្នុងវេទិកាអន្តរជាតិនាទីក្រុងកេបិច ជាទង្វើពិបាកយល់និងព្រៃផ្សៃគួរឱ្យស្អប់ខ្ពើមក្រៃលែង។ កម្ពុជាត្រូវតែការពារបូរណភាពទឹកដី ទោះត្រូវលះបង់យ៉ាងណាក៏ដោយ ប៉ុន្តែជាតិទាំងមូលមានការអត់ធ្មត់ប្រកបដោយវិចារណញ្ញាណ ដោយទុកបញ្ហានេះជូនរាជរដ្ឋាភិបាលកម្ពុជាដោះស្រាយ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី។

មេបញ្ជាការកងទ័ពកម្ពុជាជួរមុខកំពុងទាក់ទងជាមួយ
ទីបញ្ជាការ ក្រោយការប៉ះទង្គិចប្រដាប់អាវុធជាមួយ
ទាហានថៃ តុលា ២០០៨ (រូបភាព AFP)

"ទាហានកម្ពុជាមានស្មារតីខ្ពស់ក្នុងកិច្ចការពារប្រទេសរបស់ខ្លួន"
(រូបភាព និងដាក់ចំណងជើង ដោយអ្នកទេសចរបរទេស)

## ២.រវាងកម្ពុជានិងថៃ មានខ្សែបន្ទាត់ព្រំដែនអន្តរជាតិច្បាស់លាស់

តាមប្រវត្តិសាស្ត្រកម្ពុជា បញ្ហាព្រំដែនរវាងកម្ពុជានិងថៃ ព្រឹត្តិការណ៍ឆ្នាំ១៩៦២ និងប្រាសាទព្រះវិហារ បានបង្ហាញជាក់ច្បាស់ដល់អ្នកអានអំពីសច្ចភាព ដែលកងទ័ពថៃទន្ទ្រានចូលក្នុងទឹកដីកម្ពុជា ដោយបំពានធម្មនុញ្ញអង្គការសហប្រជាជាតិ និងមូលដ្ឋានគតិយុត្តិអន្តរជាតិទាំងស្រុង។

**១១ សីហា ១៨៦៣ :** សន្ធិសញ្ញាមិត្តភាពអំពីពាណិជ្ជកម្មនិងកិច្ចការពារ ( ឬសន្ធិសញ្ញាដាក់ព្រះរាជាណាចក្រកម្ពុជាក្រោមអាណាព្យាបាលបារាំង) ត្រូវបានព្រមព្រៀងនៅ រាជធានីឧត្តុង្គ (កំណត់សម្គាល់ : រហូតមកដល់ពេលនេះ ទោះបីប្រទេសសៀមប្រឹងគ្របសង្កត់លើព្រះរាជាណាចក្រកម្ពុជាយ៉ាងណាក្តី ក៏មិនមានសន្ធិសញ្ញាណាមួយរវាងកម្ពុជា និងសៀមដែរ។ វត្តមានសៀមនៅលើទឹកដីកម្ពុជា គឺជាការឈ្លានពាន ការកាន់កាប់ និងការគាបសង្កត់)។ ឧបសម្ព័ន្ធ១

**ខែ ធ្នូ ១៨៦៣ :** សន្ធិសញ្ញារវាងសៀមនិងកម្ពុជា មាត្រា១ ចែងថា " កម្ពុជាជារដ្ឋចំណុះសៀម "។ (កំណត់សម្គាល់ : កម្ពុជាត្រូវចុះហត្ថលេខាលើសន្ធិសញ្ញានេះ ក្រោមការគាបសង្កត់របស់សៀម; សៀមធ្វើការជាសម្ងាត់ មិនអោយបារាំងដឹង ដើម្បីទទួលបានការចុះហត្ថលេខាលើសន្ធិសញ្ញានេះ ក្នុងរយៈពេលប្រហែលបួនខែក្រោយសន្ធិសញ្ញា ១១ សីហា ១៨៦៣ ដែលបានព្រមព្រៀងរវាងកម្ពុជា និងបារាំងជាមុនរួចទៅហើយ)។ ឧបសម្ព័ន្ធ ២

**១៥ កក្កដា ១៨៦៧ :** សន្ធិសញ្ញារវាងសៀមនិងបារាំងបានធ្វើឡើងនៅទីក្រុងប៉ារីស ដែលមាត្រា ២ ចែងថា សន្ធិសញ្ញាចុះខែធ្នូ ១៨៦៣ រវាងសៀមនិងកម្ពុជាត្រូវចាត់ទុកជា "មោឃៈ"។ (កំណត់សម្គាល់ : ប្រទេសសៀម (បច្ចុប្បន្នថៃ) មិនអាចទាមទារភាពជាម្ចាស់លើទឹកដីកម្ពុជាដោយប្រើអំពើព្រៃផ្សៃបង្ខំកម្ពុជាឱ្យចុះហត្ថលេខាលើសន្ធិសញ្ញា តាមការគាបសង្កត់របស់សៀម ខណៈដែលកម្ពុជាមានសន្ធិសញ្ញាជាមួយបារាំងទៅហើយ)។ ឧបសម្ព័ន្ធ ៣

**៣ តុលា ១៨៩៣ :** សន្ធិសញ្ញាសន្តិភាពរវាងសាធារណរដ្ឋបារាំងទី៣ និងព្រះរាជាណាចក្រសៀម ក្រោយសង្គ្រាមដែលត្រូវបានចាប់ផ្តើមឡើងជាមួយនឹងការពង្រីកទឹកដីរបស់បារាំង ដែលគាំទ្រដោយនាវាចម្បាំង នៅខែមីនា ១៨៩៣។ នៅទីបញ្ចប់ សៀមបានយល់ព្រមធ្វើតាមលក្ខខណ្ឌបារាំងទាំងស្រុង តាមសន្ធិសញ្ញា ៣ តុលា ១៨៩៣ ព្រោះសៀមមិនអាចស្វែងរកការគាំទ្រពីអង់គ្លេសបាន។ ព្រះរាជាណាចក្រឡាវត្រូវបានរំដោះចេញពីការគ្រប់គ្រងរបស់សៀម ហើយដាក់ក្រោមអាណាព្យាបាលបារាំង។ ជាងនេះទៀត បារាំងទាមទារ និងទទួលបានកាន់កាប់ខេត្តចន្ទបូរី ជាការធានាចំពោះការអនុវត្តន៍សន្ធិសញ្ញានេះ ហើយបារាំងក៏សម្រេចបាន ឱ្យសៀមដកទ័ពខ្លួនចេញពីខេត្តបាត់ដំបងនិងសៀមរាប និងតំបន់ទំហំ២៥គីឡូម៉ែត្រលើអាងទន្លេមេគង្គភាគខាងលិច។ ឧបសម្ព័ន្ធ ៤

**១៣ កុម្ភៈ ១៩០៤ :** អនុសញ្ញាសម្រាប់ដោះស្រាយបញ្ហាលំបាកក្នុងការបកស្រាយសន្ធិសញ្ញាចុះថ្ងៃ៣ តុលា ១៨៩៣។ ចំពោះកម្ពុជា អនុសញ្ញានេះ "បានធ្វើឱ្យព្រំដែននៅតំបន់ភ្នំដងរែកភាគខាងកើតត្រឹមត្រូវតាមច្បាប់"។ តាមមាត្រា១ និងមាត្រា៣ នៃអនុសញ្ញា និងមាត្រាក្រោយមក "ការកំណត់ព្រំដែននឹងត្រូវអនុវត្តដោយគណៈកម្មការចម្រុះនៃមន្ត្រីដែលតែងតាំងឡើងដោយប្រទេសហត្ថលេខីទាំងពីរ"(ទំព័រ១៦) ហើយ "ចំពោះខ្សែព្រំដែននៅតាមជួរភ្នំដងរែកវិញ ការងាររបស់គណៈកម្មការចម្រុះផ្តង់ទៅលើតំបន់ខាងកើត នៃជួរភ្នំដងរែក (ចាប់ពីខាងកើតនៃច្រកកិល) ដែលមានប្រាសាទព្រះវិហារស្ថិតនៅទីនោះ" (ទំព័រ១៧)។

មានភស្តុតាងបង្ហាញច្បាស់ថា "រដ្ឋាភិបាលសៀមបានធ្វើសំណើជាផ្លូវការសុំឱ្យអ្នកជំនាញផែនទីបារាំងគូរផែនទីតំបន់ព្រំដែន", (ទំព័រ២០)។ មានភស្តុតាងបង្ហាញច្បាស់ថា "ផែនទីចំនួន ១១ផ្ទាំងបន្តបន្ទាប់គ្នាដែលបានគូររួចរាល់នៅចុងសរទរដូវ ឆ្នាំ១៩០៧ ដោយអ្នកជំនាញផែនទីបារាំង ត្រូវបានបញ្ជូនទៅឱ្យរដ្ឋាភិបាលសៀមនៅឆ្នាំ១៩០៨, (ទំព័រ២៩)។ គេបានចែកចាយផែនទីទាំងនោះដែលទទួលបានការយល់ព្រមយ៉ាងទូលំទូលាយ, (ទំព័រ២៣) ហើយចំពោះ "ករណីប្រាសាទព្រះវិហារ" (កម្ពុជាទល់នឹងថៃ) តុលាការរកឃើញថា អាជ្ញាធរសៀមបានទទួល

ផែនទីឧបសម្ពន្ធ័ I និងបានព្រមទទួលយកជាផ្លូវការទៀតផង.(ទំព័រ២៦)។គួរកត់សម្គាល់ថា "ផែនទីពាផ្ទាំងលែងមានសារៈសំខាន់ទៀតហើយ ដោយហេតុថា ខ្សែព្រំដែនពីមុន ត្រូវស្ថិតនៅទាំងស្រុងក្នុងទឹកដីកម្ពុជា យោងតាមសន្ធិសញ្ញាខែមីនា ឆ្នាំ១៩០៧។ នៅពេលនោះ សៀមក៏មិនចាំបាច់សម្ដែងឆន្ទៈថាខ្លួនឯកភាព ឬមិន ឯកភាពទេ "(ទំព័រ២០)។ **(យោងតុលាការយុត្តិធម៌អន្តរជាតិ, របាយការណ៍ស្ដីពីសាលដីកា មតិយល់ឃើញ និងដីកាសម្រេចនានា-សំណុំរឿងស្ដីពីប្រាសាទព្រះវិហារ 'កម្ពុជា ទល់នឹងថៃ'-អង្គសេចក្ដី-សាលដីកា ថ្ងៃ១៥ មិថុនា ១៩៦២,** ដូចនៅទំព័រខាងលើ)។ សន្ធិសញ្ញា, ឧបសម្ព័ន្ធ៥

## ផែនទីឧបសម្ព័ន្ធ I




តំបន់ប្រាសាទព្រះវិហារលើជួរភ្នំដងរែក (ផែនទីទទួលស្គាល់ដោយតុលាការយុត្តិធម៌ អន្តរជាតិ, ១៥ មិថុនា ១៩៦២)

**២៣ មីនា ១៩០៧ :** សន្ធិសញ្ញាជាកិច្ចព្រមព្រៀងចុងក្រោយនៃបញ្ហាសេសសល់ទាំងប៉ុន្មានស្តីពីបន្ទាត់ព្រំដែនរួមរវាងឥណ្ឌូចិន និងសៀម អនុលោមតាមការងារកំណត់ព្រំដែនរបស់គណៈកម្មការចម្រុះ ក្នុងការអនុវត្តអនុសញ្ញាថ្ងៃ១៣ កុម្ភៈ ១៩០៤។ តាមសន្ធិសញ្ញានេះ(១៩០៧) រដ្ឋាភិបាលសៀមត្រូវប្រគល់មកឱ្យបារាំងនូវទឹកដីខេត្តបាត់ដំបង សៀមរាប និងស៊ីសុផុន ឯបារាំងប្រគល់ទៅឱ្យសៀមនូវ ដានសេ និងក្រាត សម្រាប់ជាការដោះដូរ។ គណៈកម្មការចម្រុះទី២ ត្រូវបានបង្កើតឡើងដើម្បីកំណត់ព្រំដែនសារជាថ្មី ដោយសារការដោះដូរទឹកដី។ ព្រំដែនថ្មីត្រូវបានបែងចែកជា៥ចំណែកតូច១សម្រាប់ការកំណត់ព្រំដែន ១-ពីច្រាំងក្លុងប៉ូកូ (Klong Po ko) ទល់មុខកោះគុតទៅភ្នំធំ (Koh Kut to Phnom Thom), ២-ពីភ្នំធំទៅប៉ៃលិន, ៣-ពី ប៉ៃលិនទៅទន្លេណាមសៃ, ៤-ពីអារញ្ញទៅជួរភ្នំដងរែករហូតដល់ច្រកសាមេត និង ៥-ពីច្រកសាមេតដល់ច្រកកិល ដែល "ខ្សែ *ព្រំដែនថ្មី* គួរដោយគណៈកម្មការនេះ ជួបប្រសព្វជាមួយខ្សែបន្ទាត់ព្រំដែនមានស្រាប់ពីមុន ឆ្ពោះទៅទិសខាងកើតដល់ប្រាសាទ និងហួសពីនោះទៅទៀត "។ (ទំព័រ.១៩)

មានភស្តុតាងបញ្ជាក់ថា មន្ត្រីគណៈកម្មការសៀមដែលជាសមាជិកគណៈកម្មការចម្រុះសម្រាប់ការកំណត់ព្រំដែនបានស្នើសុំមន្ត្រីគណៈកម្មការបារាំងដែលជាសមាជិកគណៈកម្មការចម្រុះសម្រាប់ការកំណត់ព្រំដែនឱ្យ "រៀបចំផែនទីព្រំដែនដទៃទៀត "។ (ទំព័រ ២០)

**(តុលាការយុត្តិធម៌អន្តរជាតិ របាយការណ៍ស្តីពីសាលដីកា មតិយល់ឃើញ និងដីកាសម្រេចនានា-សំណុំរឿងស្តីពីប្រាសាទព្រះវិហារ 'កម្ពុជា ប្រឆាំងនិងថៃ'-អង្គសេចក្តី-សាលដីកា ថ្ងៃ១៥ មិថុនា ១៩៦២**។ សន្ធិសញ្ញា , ឧបសម្ព័ន្ធ៦

**១៤ កុម្ភៈ ១៩២៥ :** សន្ធិសញ្ញាមិត្តភាព ពាណិជ្ជកម្ម និងនាវាចរណ៍រវាងបារាំងនិងសៀម មានសុពលភាពរយៈពេល១០ឆ្នាំចាប់ពីពេលប្តូរសច្ចាប័ន (មាត្រា ២៨)។ មាត្រា ២៧ បានបញ្ជាក់និងធានាគ្នាទៅវិញទៅមកចំពោះការគោរពព្រំដែនទឹកដី ដោយអនុលោមតាមលក្ខខណ្ឌនៃសន្ធិសញ្ញាថ្ងៃ ៣ តុលា ១៨៩៣, អនុសញ្ញា ថ្ងៃ១៣ កុម្ភៈ ១៩០៤ និងសន្ធិសញ្ញា ថ្ងៃ២៣ មីនា ១៩០៧។ ឧបសម្ព័ន្ធ៧

**៩ ឧសភា ១៩៤១ :** អនុសញ្ញាក្រុងតូក្យូឆ្នាំ១៩៤១ បានផ្ទេរទឹកដីជាច្រើនរបស់បារាំងនៅឥណ្ឌូចិន ទៅឱ្យថៃ (សៀម ពីមុន) គ្រប់គ្រង។ បារាំងនិងសៀមបានព្រមព្រៀងគ្នាលើអនុសញ្ញាមួយក្រោម ការសម្រុះសម្រួលរបស់ជប៉ុន ដែលត្រូវបានចុះហត្ថលេខានៅទីក្រុងតូក្យូនៅថ្ងៃ៩ ឧសភា ឆ្នាំ១៩៤១ ដែលធ្វើឱ្យថៃទទួលបានផ្នែកនៃខេត្ត ឡាវ នៅភាគខាងលិចទន្លេមេគង្គ, ៣/៤ នៃទឹកដីខេត្ត កំពង់ធំ និងទឹកដីភាគខាងជើងប្រទេសកម្ពុជា។ ឧបសម្ព័ន្ធ៨

**១៧ វិច្ឆិកា ១៩៤៦ :** កិច្ចព្រមព្រៀងបញ្ចប់ទំនាស់រវាងបារាំងនិងសៀម ហើយអាស្រ័យកិច្ចព្រមព្រៀងនេះ អនុសញ្ញាតូក្យូថ្ងៃ៩ ឧសភា ១៩៤១ ត្រូវចាត់ទុកជាមោឃៈ ហើយទឹកដីឥណ្ឌូចិនដែលគ្រប់គ្រង ដោយអនុសញ្ញាតូក្យូ ថ្ងៃ៩ ឧសភា ១៩៤១នេះ ត្រូវប្រគល់មកឱ្យអាជ្ញាធរបារាំងវិញ។ ឧបសម្ព័ន្ធ៩

**ទាំងនេះគឺជាការពិតនិងជាសច្ចភាព។ ដោយអនុលោមតាមឧត្តមគតិរបស់អង្គការសហប្រជាជាតិ និងក្នុងប្រយោជន៍សន្តិភាពពិភពលោក ខ្សែព្រំដែន "អន្តរជាតិ" មួយត្រូវបានកំណត់រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ហើយគឺជាគោលបំណងចម្បងមួយដើម្បីសម្រេចបានភាពច្បាស់លាស់និងស្ថាពរ។ "ផែនទីភ្នំដងរែក" ឬ "ផែនទីឧបសម្ព័ន្ធ I" ជាចំណែកដ៏សំខាន់ក្នុងការបញ្ជាក់អំពីខ្សែព្រំដែន "អន្តរជាតិ" ទទួលស្គាល់ដោយភាគីសៀមនិងភាគីបារាំង និងអ្នកបន្តវេនពីបារាំង គឺព្រះរាជាណាចក្រកម្ពុជា។**

## ៣. ប្រាសាទព្រះវិហារ

### ១៩៦២ : ឆ្នាំនៃសេចក្តីសម្រេចចិត្ត

ប្រាសាទព្រះវិហារស្ថាបនាឡើងក្នុងសម័យអង្គរ ជាកម្មសិទ្ធិរបស់ប្រទេសកម្ពុជាតាំងពីពេលកសាងឡើងក្នុងសតវត្សទី១១។ ប៉ុន្តែ ប្រទេសថៃបានចូលមកគ្រប់គ្រងជាបណ្តោះអាសន្ននូវផ្នែកខ្លះនៃប្រទេសកម្ពុជា ដោយរួមមានទាំងប្រាសាទព្រះវិហារ និងតំបន់ជុំវិញប្រាសាទផង ក្នុងអំឡុងសង្គ្រាមលោកលើកទី២។ ក្រោយសង្គ្រាម តាមរយៈកិច្ចព្រមព្រៀងបញ្ចប់ទំនាស់ជាមួយបារាំង ថៃបានយល់ព្រមទទួលយកការវិលត្រឡប់ទៅកាន់ស្ថានភាពបែងចែកទឹកដី ដែលមានពីមុនពីឆ្នាំ១៩៤១ វិញ។ ក៏ប៉ុន្តែ ដោយសារថៃរំលោភបំពានលើកិច្ចព្រមព្រៀងនេះ ទើបថៃបានបន្តវត្តមានទាហានរបស់ខ្លួននៅប្រាសាទ និងទីជិតខាងក្បែរប្រាសាទ ដែលនៅទីបំផុតជំរុញឱ្យកម្ពុជាដាក់បញ្ហានេះទៅតុលាការយុត្តិធម៌អន្តរជាតិក្នុងឆ្នាំ១៩៥៩។

នៅថ្ងៃ១៥ មិថុនា ១៩៦២ តុលាការយុត្តិធម៌អន្តរជាតិបានចេញសាលដីកាលើរឿងក្តីនេះ ដោយសម្រេចថា ប្រាសាទដ៏ល្បីល្បាញនេះ "ស្ថិតនៅក្នុងទឹកដីក្រោមអធិបតេយ្យរបស់កម្ពុជា "។ ជាងនេះទៅទៀត សាលដីកាបានតម្រូវឱ្យថៃដកទ័ពចេញពីប្រាសាទ "និងទីជិតខាងក្បែរប្រាសាទក្នុងទឹកដីកម្ពុជា "។

តុលាការអន្តរជាតិទីក្រុងឡាអេ



INTERNATIONAL COURT OF JUSTICE

REPORTS OF JUDGMENTS,
ADVISORY OPINIONS AND ORDERS

CASE CONCERNING THE
TEMPLE OF PREAH VIHEAR
(CAMBODIA v. THAILAND)
MERITS

JUDGMENT OF 15 JUNE 1962

1962

COUR INTERNATIONALE DE JUSTICE

RECUEIL DES ARRÊTS,
AVIS CONSULTATIFS ET ORDONNANCES

AFFAIRE DU TEMPLE DE
PRÉAH VIHÉAR
(CAMBODGE c. THAÏLANDE)
FOND

ARRÊT DU 15 JUIN 1962

សៀវភៅសាលដីកា រឿងក្តីប្រាសាទព្រះវិហារ
បោះពុម្ពផ្សាយដោយតុលាការយុត្តិធម៌អន្តរជាតិ (បោះពុម្ពនៅហូឡង់)




ក្នុងអង្គជំនុំតុលាការអន្តរជាតិស្តីពី ប្រាសាទព្រះវិហារ
មេធាវីភាគីកម្ពុជា: ពីឆ្វេងទៅស្តាំ: មេធាវី រ៉ូទែរ, មេធាវី ពីនតូ, មេធាវី
អាឆេសុន និង ឯកឧត្តម ទ្រឿង កាង តំណាងរាជរដ្ឋាភិបាលកម្ពុជា
(រូបថតអនុស្សាវរីយ៍ សម្តេចព្រះមហាវីរក្សត្រ នរោត្តម សីហនុ)

មូលហេតុនៃការសម្រេចរបស់តុលាការមានចែងនៅក្នុងសាលដីកា។ នៅផ្នែកខាងដើមនៃសាលដីកានោះ តុលាការយុត្តិធម៌អន្តរជាតិបានលើកឡើងថា តុលាការអាច *"ធ្វើការសម្រេចស្តីពីអធិបតេយ្យភាពលើតំបន់ប្រាសាទទៅបាន បន្ទាប់ពីបានពិនិត្យខ្សែព្រំដែន"*។

តុលាការបានរកឃើញថា ក្នុងឆ្នាំ១៩០៤ រដ្ឋាភិបាលសៀម (ថៃ) និងបារាំង (អាណាព្យាបាលលើប្រទេសកម្ពុជា) បានចុះហត្ថលេខាលើអនុសញ្ញាឱ្យស្រាវជ្រាវវាស់វែង និងកំណត់ព្រំដែនកម្ពុជា និងថៃ។ គណៈកម្មការចម្រុះបារាំង-សៀមត្រូវបានបង្កើតឡើងដើម្បីគូរផែនទីព្រំដែន ហើយផែនទី ១១ ផ្ទាំងត្រូវបានគូរឡើង។

ផែនទីតំបន់ដងរែក (រួមទាំងតំបន់ព្រំដែនជាប់ប្រាសាទផង ហើយត្រូវបានសំគាល់វាជា **ផែនទីឧបសម្ព័ន្ធ I**) ត្រូវបានបញ្ចប់រួចរាល់នៅចុងសរទរដូវ ឆ្នាំ១៩០៧ នៅពេលដែលសន្ធិសញ្ញា ចុះថ្ងៃ២៣ មីនា ១៩០៧ ចូលជាធរមាន ឱ្យមានកិច្ចព្រមព្រៀងជាទីបញ្ចប់អំពីបញ្ហាទឹកដីរវាងបារាំងនិងសៀម។ បន្ទាប់ពីការពិនិត្យយ៉ាងហ្មត់ចត់អំពីប្រវត្តិផែនទី និងកាលៈទេសៈនៃការគូរផែនទីនោះមក តុលាការសម្រេចថា មានចំណុចសង្ស័យតិចតួចណាស់អំពីប្រភពផែនទី ៖ ហើយ "អ្វីដែលជាក់ច្បាស់នោះ គឺថាផែនទីមានមូលដ្ឋានមួយពិតប្រាកដ ហើយតុលាការគិតថាមិនអាចមានការសង្ស័យ ប្រកបដោយវិចារណញ្ញាណណាមួយឡើយ ព្រោះថា ផែនទីត្រូវបានគូរឡើងដោយពឹងផ្អែកលើការវាស់វែងនៅផ្នែកភ្នំដងរែកដោយមន្ត្រីជំនាញ"។

ទោះបីបែបនេះក្តី ការណ៍ដែលផែនទីត្រូវបានផលិតក្រោយពីគណៈកម្មការត្រូវរំលាយ ដែលមើលទៅហាក់ដូចជាមិនសមស្របទៅនឹងអត្ថបទ នៃអនុសញ្ញាឆ្នាំ១៩០៤ ដែលនិយាយពីការកំណត់ព្រំដែនតាមខ្សែបែងចែកទឹកក៏ដោយ សំណួរត្រូវបានចោទឡើងថា តើផែនទីអាចត្រូវយកទៅប្រើបានប្រកបដោយសុពលភាពឬទេ ក្នុងកាលៈទេសៈនេះ។ តុលាការបានបញ្ចេញទស្សនៈរបស់ខ្លួនថា ៖

**"ដូច្នេះ សំណួរដែលមានសារៈសំខាន់ពិតប្រាកដក្នុងករណីនេះគឺថា តើភាគីទាំងពីរបានទទួលស្គាល់ផែនទីឧបសម្ព័ន្ធ I និងខ្សែព្រំដែននៅលើផែនទីនោះ ដែលជាលទ្ធផលនៃការងារកំណត់ព្រំដែននៅតំបន់ប្រាសាទព្រះវិហារ ឬទេ។ ដោយសារថាផែនទីត្រូវបានទទួលស្គាល់ហើយនោះ ភាគីទាំងពីរត្រូវចាត់ទុកថាជាប់កាតព្វកិច្ច"។**

សំខាន់ជាងនេះទៅទៀត តាមការយល់ឃើញរបស់តុលាការ ផែនទីនេះត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលទាំងពីរថាជា ផែនទីខ្សែព្រំដែន។ ក្នុងសាលដីកា តុលាការបានរៀបរាប់អំពីការផ្សព្វផ្សាយផែនទីឧបសម្ព័ន្ធ I នៅក្នុងរង្វង់រដ្ឋាភិបាលថៃ ហើយក៏មានការទទួលយកខ្សែព្រំដែនដដែលនេះ នៅលើផែនទីបន្តបន្ទាប់មកទៀត ដែលបានផលិតដោយរាជមន្ទីរស្រាវជ្រាវភូមិសាស្ត្រថៃ។

ក្នុងប្រវត្តិលំអិតពីការឯកភាពលើផែនទីដោយអាជ្ញាធរថៃ តុលាការបានរៀបរាប់អំពីឱកាសជាច្រើនដែលអាជ្ញាធរថៃមាន ដើម្បីបដិសេធចោលផែនទីគូរដោយគណៈកម្មការចម្រុះ ប៉ុន្តែអាជ្ញាធរថៃមិនបានធ្វើដូច្នេះទេ។ ក្រោយមក ការវិនិច្ឆ័យក្នុងចំនុចនេះ បានក្លាយទៅជាគោលការណ៍ច្បាប់ដ៏សំខាន់ក្នុងច្បាប់អន្តរជាតិ គឺ**គោលការណ៍យល់ព្រមដោយស្ងៀមស្ងាត់**។

ប្រទេសថៃជំទាស់ទៅលើការប្រើប្រាស់ផែនទីឧបសម្ព័ន្ធ I ដោយអះអាងថា សន្ធិសញ្ញាឆ្នាំ១៩០៤ បានកំណត់ថា ខ្សែព្រំដែនត្រូវគូរតាមខ្សែបែងចែកទឹក ហើយផែនទីឧបសម្ព័ន្ធ I នេះ មិនបានគូរតាមទេ។ ជាពិសេសតុលាការ បានទាត់ចោលទឡ្ហីករណ៍របស់ថៃ ពាក់ព័ន្ធទៅលើការណ៍ដែលផែនទីនេះ មិនត្រូវបានគូសតាមខ្សែបែងចែកទឹក ដោយបានកំណត់បញ្ជាក់ថា៖ "**គឺប្រាកដជានៅក្នុងរង្វង់អំណាចទាំងឡាយរបស់រដ្ឋាភិបាល ដែលបានព្រមព្រៀងជាមួយគ្នា ប្រកាន់យកការឃ្លាតវាតចេញពីខ្សែបែងចែកទឹកនេះ**"។

ផ្អែកទៅលើរាល់ភស្តុតាងទាំងប៉ុន្មាន តុលាការយុត្តិធម៌អន្តរជាតិបានសន្និដ្ឋានថា "**ប្រទេសថៃ នៅឆ្នាំ១៩០៨-១៩០៩ បានទទួលផែនទីឧបសម្ព័ន្ធ I ដែលជាលទ្ធផលការងារនៃការកំណត់ព្រំដែន និងបានទទួលស្គាល់ថា គំនូសព្រំដែនលើផែនទី គឺជាខ្សែព្រំដែនពិតប្រាកដ ហើយអាស្រ័យខ្សែព្រំដែននេះ ប្រាសាទព្រះវិហារត្រូវបានបញ្ជាក់ថា ស្ថិតនៅក្នុងទឹកដីរបស់កម្ពុជា**"។ តុលាការបានសន្និដ្ឋានទៀតថា "**ការទទួលស្គាល់ផែនទីឧបសម្ព័ន្ធ I ដោយភាគីទាំងពីរ ជាមូលហេតុអាចឱ្យតុលាការបញ្ចូលផែនទីក្នុងសន្ធិសញ្ញា ហើយផែនទីក៏ក្លាយជាផ្នែកទាំងស្រុងរបស់សន្ធិសញ្ញានោះ**"។

## ៤_គោលនយោបាយឈ្លានពានពីររបស់ថៃ ទាក់ទងនឹងប្រាសាទព្រះវិហារ

ផលវិបាកនៃការចាញ់ក្តីនៅតុលាការយុត្តិធម៌អន្តរជាតិគឺជាសោកនាដកម្មរបស់ប្រទេសថៃ។ យោងតាមកំណត់ត្រាពីរឿងរ៉ាវនៅពេលនោះបានបញ្ជាក់ថា មាន **"ការតវ៉ាដែលមាន លក្ខណៈហិង្សា និងយុទ្ធនាការផ្សព្វផ្សាយព័ត៌មានយ៉ាងខ្លាំងក្លា"** ។ បាតុកម្ម និងការដង្ហែក្បួនជាច្រើនត្រូវបានរៀបចំឡើងប្រឆាំងនឹងសាលដីការបស់តុលាការយុត្តិធម៌អន្តរជាតិ។ និស្សិតនៅសាកលវិទ្យាល័យ ធម្មសាត (Thammasart University) នៅទីក្រុងបាងកកទាមទារឱ្យដកព្រះនាមរបស់សម្តេចព្រះ **នរោត្តម សីហនុ** ចេញពីបញ្ជីឈ្មោះរបស់សាកលវិទ្យាល័យ ហើយទទួចឱ្យដកហូតសញ្ញាបត្រកិត្តិយសដែលបានប្រគល់ថ្វាយព្រះអង្គផងដែរ។ នៅពេលនោះសម្តេចព្រះ **នរោត្តម សីហនុ** សម្រេចព្រះទ័យប្រគល់សញ្ញាបត្រត្រឡប់ទៅឱ្យសាកលវិទ្យាល័យនោះវិញ។

ក្នុងរវាងចុងខែមិថុនា ១៩៦២ និងបន្ទាប់ពីមានការពិភាក្សាផ្ទៃក្នុងជាច្រើនដង រដ្ឋាភិបាលថៃបានប្រកាសថា ខ្លួននឹងគោរពកាតព្វកិច្ចរបស់ខ្លួនតាមធម្មនុញ្ញអង្គការសហប្រជាជាតិ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងលិខិតផ្ញើទៅលោក **អ៊ូ ថាន់** (U Thant) អគ្គលេខាធិការអង្គការសហប្រជាជាតិ លោក **ថាណាត់ ខូម៉ាន់** (Thanat Khoman) រដ្ឋមន្ត្រីការបរទេសថៃ បានសរសេរថា ថៃរក្សាសិទ្ធិគ្រប់យ៉ាងដែលខ្លួនមាន ឬអាចមាននៅពេលអនាគតដើម្បីទាមទារយកប្រាសាទមកវិញ។

ដូច្នេះ ការសម្រេចចិត្តរបស់ថៃក្នុងការគោរពតាមដីកាសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិ គឺជាការបណ្តោះអាសន្ន។ សូម្បីមានការយល់ព្រមនឹងសេចក្តីសម្រេចរបស់តុលាការនិងមានការដកទ័ពរបស់ខ្លួនចេញរួចទៅហើយក្តី ក៏ជាការច្បាស់ណាស់ថា បន្ទាប់ពីនោះថៃបានបណ្តុះក្តីសង្ឃឹមក្នុងការទាមទារយកប្រាសាទព្រះវិហារនៅថ្ងៃអនាគត។ យោងតាមកំណត់ត្រាមួយអំពីប្រតិកម្មរបស់ថៃ "ជាការគួរឱ្យកត់សម្គាល់ដែលទង់ជាតិ និងដងទង់ជាតិរបស់ថៃបានដកចេញពីប្រាសាទក្នុងលក្ខណៈបញ្ឈរហូត ហើយក្រោយមកបានយកទៅរក្សាទុកក្នុងសារៈមន្ទីររបស់ថៃ។ ការជំទាស់មិនព្រមទម្លាក់ទង់ជាតិថៃ ត្រូវបានអ្នកសង្កេតការណ៍ជាច្រើននៅសម័យនោះមើលឃើញថា ប្រទេសថៃនៅតែចិញ្ចឹមចិត្តលើកទង់ជាតិខ្លួននៅលើប្រាសាទវិញនៅថ្ងៃអនាគត" ។

ទោះបីជារយៈពេល១០ឆ្នាំ សម្រាប់ប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិ បានអស់សុពលភាពទៅហើយក្តី ក៏ហេតុការណ៍នេះ មិនបានធ្វើឱ្យថៃលះបង់គំនិតយកប្រាសាទព្រះវិហារវិញដែរ។ ចិត្តគំនិតនេះបានលេចច្បាស់ នៅក្នុងពេលដែលមានសង្គ្រាមស៊ីវិលនៅកម្ពុជា ដែលខណៈនោះមានសេចក្តីរាយការណ៍ថា ឥស្សរជននៃរដ្ឋាភិបាលថៃបានជម្រុញឱ្យមានកិច្ចព្រមព្រៀងមួយជាមួយមេដឹកនាំក្រុមបក្សខ្មែរនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ លើការប្រគល់ប្រាសាទព្រះវិហារទៅឱ្យថៃ ក្នុងករណីក្រុមបក្សទាំងនោះអាចដណ្តើមអំណាចបាននៅភ្នំពេញ ដើម្បីជាថ្នូរនឹងការជួយទំនុកបម្រុងបន្តទៀតពីប្រទេសថៃ។

ប៉ុន្តែបច្ចុប្បន្ននេះបង្ហាញច្បាស់ថា ក្នុងករណីដែលគេមិនអាចយកប្រាសាទទាំងស្រុងបាន ថៃបានមានគម្រោងទីពីរជាស្រេច គឺការទាមទារសិទ្ធិលើដីនៅជុំវិញប្រាសាទ។ ពេលដែលកម្ពុជាស្នើចុះប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅឆ្នាំ២០០៧ រាជរដ្ឋាភិបាលថៃអនុវត្តគម្រោងដែលបានលើកឡើងខាងលើ។

នៅសម័យប្រជុំលើកទី៣១ របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក នៅក្រៃស្ទឹច ប្រទេសណូវែលហ្សេឡង់ ថៃបានជំទាស់នឹងការចុះប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ហើយស្នើឱ្យពន្យាពេលនៃការចុះបញ្ជីនេះ។ នៅពេលនោះ ប្រទេសថៃបានបញ្ចេញផែនទីមួយផ្សេងពីផែនទីដែលបានប្រើ និងទទួលស្គាល់ដោយតុលាការយុត្តិធម៌អន្តរជាតិ ក្នុងការសម្រេចក្តីលើករណីអធិបតេយ្យលើប្រាសាទព្រះវិហារ។ នៅក្នុងផែនទីថ្មីរបស់ថៃ ព្រំដែនរវាងប្រទេសទាំងពីរគឺនៅជាប់នឹងគែមរចនាសម្ព័ន្ធប្រាសាទមិនមែននៅឆ្ងាយដូចក្នុងករណីផែនទីឧបសម្ព័ន្ធ I របស់តុលាការយុត្តិធម៌អន្តរជាតិនោះទេ។

គណៈកម្មាធិការបេតិកភណ្ឌពិភពលោកនិងភាគីទាំងពីរ បានឯកភាពធ្វើការពន្យាពេលចុះបញ្ជីប្រាសាទព្រះវិហាររហូតដល់កិច្ចប្រជុំឆ្នាំក្រោយនៅទីក្រុងកេបិច ប្រទេសកាណាដា ហើយគណៈប្រតិភូថៃបានយល់ព្រមគាំទ្រការចុះប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៃសម័យប្រជុំលើកក្រោយ។ ក្នុងរយៈពេលមួយឆ្នាំក្រោយពីកិច្ចប្រជុំនៅក្រៃស្ទឹច រដ្ឋាភិបាលកម្ពុជា

និងអ្នកជំនាញឯកទេស បានធ្វើការងារលើបញ្ហាដែលបានពិភាក្សានៅក្រែឆឹច និងកែលំអឯកសារមុនការចុះបញ្ជីប្រាសាទនៅសម័យប្រជុំគណៈកម្មាធិការបេតិកភណ្ឌ នៅទីក្រុងកេបិច ឆ្នាំ២០០៨។

ពេលដែលសម័យប្រជុំលើកទី៣២របស់គណៈកម្មាធិការបេតិភណ្ឌពិភពលោកនៅទីក្រុងកេបិចជិតឈានមកដល់ ប្រទេសថៃបានបញ្ជាក់ជាថ្មីនូវការគាំទ្ររបស់ខ្លួនចំពោះ ការចុះប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ នៅក្នុងសេចក្តីប្រកាសរួមមួយដែលបានចុះហត្ថលេខានៅថ្ងៃ១៨ មិថុនា ២០០៨ ដោយរដ្ឋមន្ត្រីការបរទេសថៃ ឯកឧត្តម **ណុបផាដុន បាតាម៉ា** (Noppadon Pattama) និងឯកឧត្តមឧបនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បណ្ឌិត **សុខ អាន** ហើយដោយមានអ្នកតំណាងយូណេស្កូធ្វើជាសាក្សីផងនោះ ថៃនៅតែអះ អាងពីការគាំទ្ររបស់ខ្លួនសម្រាប់ការចុះបញ្ជីប្រាសាទនេះ។

កិច្ចប្រជុំនៅទីស្នាក់ការកណ្តាលរបស់អង្គការយូណេស្កូក្នុងទីក្រុងប៉ារីស នាថ្ងៃ២២ ខែឧសភា ឆ្នាំ២០០៨ រវាង ឯកឧត្តម បណ្ឌិត **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង ឯកឧត្តម **ណុបផាដុន ប៉ាតាម៉ា** រដ្ឋមន្ត្រីក្រសួងការបរទេស នៃរាជរដ្ឋាភិបាលថៃ ដោយមានវត្តមានរបស់លោកជំទាវ **ហ្វ្រង់ស្វ័រ រីវិយែរ** អគ្គនាយករងអង្គការយូណេស្កូ ផ្នែកវប្បធម៌ និង ឯកឧត្តមអគ្គរដ្ឋទូត **ហ្វ្រង់សីស្កូ ការុសូ**
(រូបថតៈ ទីស្តីការគណៈរដ្ឋមន្ត្រី-រាជរដ្ឋាភិបាលកម្ពុជា)

(បកប្រែក្រៅផ្លូវការ)

# សេចក្តីថ្លែងការណ៍រួម

នៅថ្ងៃ២២ ឧសភា ២០០៨ កិច្ចប្រជុំមួយបានប្រារព្ធឡើងរវាង ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម ណុបផាដុន ប៉ាតាម៉ា រដ្ឋមន្ត្រីការបរទេសថៃ ដើម្បីបន្តការពិភាក្សារបស់ខ្លួនទាក់ទងនឹងការចុះប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ កិច្ចប្រជុំនេះបានធ្វើឡើងនៅទីស្នាក់ការ យូណេស្កូនៅប៉ារីស នៅចំពោះមុខលោកជំទាវ Françoise Rivière អគ្គនាយករងអង្គការយូណេស្កូ ផ្នែកវប្បធម៌, លោកឯកអគ្គរដ្ឋទូត Francesco Caruso. លោក Azedine Beschaouch , លោកស្រី Paola Leoncini Bartoli និងលោក Giovanni Boccardi ។

កិច្ចប្រជុំបានប្រព្រឹត្តទៅក្នុងស្មារតីមិត្តភាពនិងសហប្រតិបត្តិការ។

ក្នុងអំឡុងពេលនៃកិច្ចប្រជុំនេះ ភាគីទាំងពីរបានឯកភាពដូចតទៅ :

១ ព្រះរាជាណាចក្រថៃគាំទ្រការចុះប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក នៅសម័យប្រជុំលើកទី៣២ របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក (ទីក្រុងកេបិច កាណាដា ខែកក្កដា ២០០៨) ដែលស្នើឡើងដោយព្រះរាជាណាចក្រកម្ពុជាដែលបានកំណត់ជា N.1 នៅក្នុងផែនទីដែលរៀបចំឡើងដោយអាជ្ញាធរកម្ពុជាដូចដែលបានភ្ជាប់មកជាមួយ។ ផែនទីបានបញ្ចូលផងដែរនូវតំបន់ការពារខាងកើត និងខាងត្បូងប្រាសាទដែលបានកំណត់ជា N.2 ។

២ ក្នុងស្មារតីមិត្តភាពនិងការសម្រុះសម្រួល ព្រះរាជាណាចក្រកម្ពុជាឯកភាពថា ដាក់ស្នើសុំចុះប្រាសាទព្រះវិហារចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ដោយមិនមានផ្នែកតំបន់ការពារនៅភាគខាងជើង និងខាងលិចរបស់ប្រាសាទទេ។

៣ ផែនទីដែលបានលើកឡើងនៅកថាខណ្ឌទី១ ខាងលើ នឹងត្រូវជំនួសផែនទីអំពី "សេម៉ាមេសម្រាប់តំបន់ប្រាសាទព្រះវិហារ (Schéma Directeur pour le Zonage de Preah Vihear)" ព្រមទាំងរាល់សេចក្តីបញ្ជាក់ក្រាហ្វិចទាំងអស់ដែលចង្អុលបង្ហាញ "តំបន់មូលដ្ឋាន" និងតំបន់ដទៃទៀត នៃប្រាសាទព្រះវិហារនៅក្នុងឯកសារដាក់ស្នើចុះឈ្មោះរបស់កម្ពុជា។

៤ ក្នុងអំឡុងពេលរង់ចាំលទ្ធផលការងាររបស់គណៈកម្មការចំរុះព្រំដែនដីគោក (JBC) ស្តីពីតំបន់ភាគខាងជើង និងខាងលិចតំបន់ប្រាសាទព្រះវិហារ ដែលត្រូវបានកំណត់សម្គាល់ជា N.3 នៅក្នុងផែនទីដែលបានលើកឡើងក្នុងកថាខណ្ឌទី១ ខាងលើ គម្រោងគ្រប់គ្រងតំបន់ទាំងនោះនឹងត្រូវរៀបចំក្នុងលក្ខណៈព្រមព្រៀងគ្នារវាងអាជ្ញាធរកម្ពុជានិងថៃ ដោយអនុលោមតាមគំរូអភិរក្សជាអន្តរជាតិជាមួយនឹងទស្សនៈដើម្បីថែរក្សាតម្លៃសាកលមហាស្ចារ្យរបស់សម្បត្តិនេះ។ គម្រោងគ្រប់គ្រងនេះ នឹងបញ្ចូលក្នុងគម្រោងគ្រប់គ្រងចុងក្រោយចំពោះប្រាសាទនិងតំបន់ជុំវិញនោះ ដើម្បីបញ្ជូនទៅមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោកត្រឹម ថ្ងៃ០១ ខែកុម្ភៈ ឆ្នាំ២០១០ សម្រាប់ការពិចារណារបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោកនៅសម័យប្រជុំលើកទី៣៤ ឆ្នាំ២០១០។

៥ ការចុះប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក មិនមានប៉ះពាល់ដល់សិទ្ធិរបស់ព្រះរាជាណាចក្រកម្ពុជានិងព្រះរាជាណាចក្រថៃ លើការងារកំណត់ខ័ណ្ឌសីមាព្រំដែនរបស់គណៈកម្មការរួមសម្រាប់ព្រំដែនគោក (JBC) របស់ប្រទេសទាំងពីរទេ។

៦ ព្រះរាជាណាចក្រកម្ពុជានិងព្រះរាជាណាចក្រថៃសូមសំដែងនូវការកោតសរសើរយ៉ាងជ្រាលជ្រៅរបស់ខ្លួនចំពោះអគ្គនាយកអង្គការយូណេស្កូ ឯកឧត្តម Koïchiro Matsuura ក្នុងការជួយជ្រោមជ្រែង ដ៏សប្បុរសរបស់លោកដើម្បីសម្របសម្រួលដំណើរការនេះ ឈានទៅរកការចុះឈ្មោះប្រាសាទព្រះវិហារ ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

*Phnom Penh, 18 June 2008*

For the Royal Government of Cambodia,

H.E. Mr. SOK AN
Deputy Prime Minister,
Minister in charge of the Office of the Council of Ministers

*Bangkok, 18 June 2008*

For the Government of the Kingdom of Thailand,

H.E. Mr. NOPPADON PATTAMA
Minister of Foreign Affairs

*Paris, 18 June 2008*

Representative of the UNESCO

Françoise Rivière
Assistant Director-General for Culture

ជាអកុសល នៅពេលកិច្ចប្រជុំគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ឆ្នាំ២០០៨ នៅប្រទេសកាណាដាជិតមកដល់ ចលាចលនយោបាយនៅទីក្រុងបាងកកបានធ្វើឱ្យរដ្ឋាភិបាលថៃដកការគាំទ្ររបស់ខ្លួនជាថ្មីម្តងទៀតពីការស្នើចុះប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ផ្ទុយពីការសន្យានៅក្រែឆឹច។ ក្នុងការជជែកវែកញែកខាងនយោបាយដ៏ក្តៅគគុកនៅ ទីក្រុង បាងកក មុនកិច្ចប្រជុំគណៈកម្មាធិការបេតិកភណ្ឌពិភពលោក រដ្ឋាភិបាលថៃបានបង្ហាញទាំងបំពាននូវផែនទីដែលគូរខ្សែព្រំដែនចូលយ៉ាងជ្រៅក្នុងទឹកដីកម្ពុជា ហួសខ្សែព្រំដែនដែលថៃ បានទទួលស្គាល់ពីមុនមក។

នៅពេលនេះអ្វីៗត្រូវបានលាតត្រដាង ដោយអាជ្ញាធរនៃរាជរដ្ឋាភិបាលថៃឱ្យដឹងថា ផែនទីដែលគេបានគូរជា **ឯកតោភាគី** **បង្ហាញពី**តរិយាបថយូរអង្វែងមកហើយរបស់រដ្ឋាភិបាលថៃ។ ជាឧទាហរណ៍ ក្រសួងការបរទេសថៃលើកឡើងថា ផែនទីឯកតោភាគី បង្ហាញពីគោលជំហររបស់រដ្ឋាភិបាលថៃ ចំពោះព្រំដែន បន្ទាប់ពីមានសេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ១៩៦២។ ប៉ុន្តែ ចំពោះផែនទីដែលបានបង្កើតឡើង និងអនុម័តជា **ឯកតោភាគី** ដោយរដ្ឋាភិបាលថៃនោះ មិនមានការផ្សព្វផ្សាយក្រោយពីការសម្រេចកាត់សេចក្តីរបស់តុលាការយុត្តិធម៌អន្តរជាតិឱ្យដឹងថា នេះជាការយល់ឃើញពិតប្រាកដរបស់ថៃស្តីពីបញ្ហាព្រំដែននោះឡើយ។




អស់រយៈពេលជាង៤០ឆ្នាំ ថៃមិនដែលបានជំទាស់ជាចំហទៅនឹងខ្សែព្រំដែន បញ្ជាក់ឡើងដោយតុលាការយុត្តិធម៌អន្តរជាតិឡើយ។ ការណ៍ដែលថៃរក្សាទុកផែនទីឯកតោភាគីមិនឱ្យដឹងជាសាធារណៈ ត្រូវបានបកស្រាយឱ្យដឹងអំពីមូលហេតុ តាមការបង្ហាញឱ្យឃើញថ្មីៗថែមទៀតនូវផែនទីដែលផលិតឡើងដោយរាជមន្ទីរស្រាវជ្រាវភូមិសាស្ត្រថៃ ក្នុង




ផែនទីតំបន់ **ឯកតោភាគី** រៀបចំ និង បង្ហាញដោយព្រះរាជាណាចក្រថៃនាពេលថ្មីៗនេះ។ តំបន់ផ្ទៃពណ៌លឿងបង្ហាញពីការទាមទាររបស់ថៃ។




ផែនទីដែលប្រើប្រាស់ដោយព្រះរាជាណាចក្រកម្ពុជាផ្អែកលើផែនទីដែលទទួលស្គាល់ដោយតុលាការយុត្តិធម៌អន្តរជាតិដែលជាផ្នែកមួយនៃសេចក្តីសម្រេចថ្ងៃ១៥ ខែមិថុនា ឆ្នាំ១៩៦២

អំឡុងពេលដែលកម្ពុជាកំពុងឆ្លងកាត់សង្គ្រាមក្នុងប្រវត្តិសាស្ត្រថ្មីៗនេះរបស់ខ្លួន។ ទោះបីជាមិនមានកាលបរិច្ឆេទនៅលើផែនទីក្តី ក៏ជាការបញ្ជាក់ច្បាស់ណាស់ថា **ផែនទីឯកតោភាគី** នោះ ត្រូវបានបង្កើតឡើងនៅក្នុងពេលមួយ នៅចន្លោះពីរបបខ្មែរក្រហម ឆ្នាំ១៩៧៥ ដល់ពេលចប់សង្គ្រាមនៅកម្ពុជានាចុងទសវត្សឆ្នាំ១៩៩០។ ករណីនេះច្បាស់ណាស់ ព្រោះក្នុង **ផែនទីឯកតោភាគី** តាមខ្សែបន្ទាត់ព្រំដែនខាងកម្ពុជា មានពាក្យ **"កម្ពុជាប្រជាធិបតេយ្យ"** គឺជាឈ្មោះរបស់ប្រទេសកម្ពុជា ដែលប្រើដោយរដ្ឋាភិបាលខ្មែរក្រហម។

ខ្សែព្រំដែននៅលើផែនទី ដែលមានកំណត់អត្តសញ្ញាណកម្ពុជា ជា "កម្ពុជាប្រជាធិបតេយ្យ" គឺដូចគ្នាទៅនឹងព្រំដែន នៅលើ **ផែនទីឯកតោភាគី** ពេលបង្ហាញឡើងនៅសម័យប្រជុំគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ទីក្រុងក្រៃឆឹច ណូវែលហ្សេឡង់ និងផ្សព្វផ្សាយជាសាធារណៈ ដោយរាជរដ្ឋាភិបាលថៃនៅមុនកិច្ចប្រជុំលើកក្រោយនៅទីក្រុងកេបិច កាណាដា។ ប៉ុន្តែ ផែនទីដែលបង្កើតឡើងដោយរាជមន្ទីរស្រាវជ្រាវ ភូមិសាស្ត្រថៃ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ មានកំណត់សម្គាល់ថា **"សម្ងាត់"** ជាភាសាថៃ។ មានន័យថា រាជមន្ទីរស្រាវជ្រាវភូមិសាស្ត្រថៃ ព្រមានអ្នកប្រើផែនទីនេះឱ្យលាក់បាំងពីភ្នែកសាធារណៈជន។

(ចំណងជើង ដែលដាក់លើផែនទីថៃមានព្រំដែនជាមួយ "កម្ពុជាប្រជាធិតេយ្យ" អានទាំងស្រុងជាភាសាថៃ : *"រំឭក : ផែនទីនេះជាឯកសារសម្ងាត់។ អ្នកប្រើប្រាស់ផែនទីនេះ ត្រូវរក្សាផែនទីនេះទុកដោយប្រុងប្រយ័ត្ន ដើម្បីសុវត្ថិភាពប្រទេសថៃ"*)។

គឺជាការខកចិត្តក្រៃលែងចំពោះឥស្សរជនថៃដែលយកប្រាសាទព្រះវិហារវិញមិនបាន នៅពេលដែលកម្ពុជាសម្រេចបានសន្តិភាព។ ប៉ុន្តែ ថៃបានរក្សាទុកផែនទីព្រំដែនជិតប្រាសាទព្រះវិហារជាសម្ងាត់ ហើយរង់ចាំឱកាសដែលគេអាចរំកិលមហិច្ឆតាទឹកដីរបស់គេ និងអាចទន្ទ្រានទឹកដីនៅជិតប្រាសាទ។ បើថៃមិនអាចយកប្រាសាទបានទេ នោះថៃតាំងចិត្តថា គេត្រូវតែគ្រប់គ្រងដីនៅជុំវិញនោះឱ្យបាន។

ឱកាសបានមកដល់តាមរយៈការចុះប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៅទីក្រុងកេបិច ថ្ងៃ០៧ កក្កដា ២០០៨។ ដោយការសម្រេចជាឯកច្ឆន្ទរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក ប្រាសាទព្រះវិហារត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ បញ្ហានេះបានធ្វើឱ្យរដ្ឋមន្ត្រីការបរទេសថៃដែលដឹកនាំគណៈប្រតិភូផ្ទុះចេញនូវកំហឹងយ៉ាងអាក្រក់។ ចំពោះហេតុការណ៍កើតឡើងក្រោយនេះ ប្រធានគណៈកម្មាធិការបេតិកភណ្ឌថៃបានថ្លែងសុន្ទរកថាបែបខឹងសម្បារយ៉ាងខ្លាំង។ មិនមានការទះដៃអបអរសាទរ ឬសម្តែងការគួរសមពីអង្គប្រជុំឡើយ ហើយគណៈប្រតិភូថៃដែលមិនសប្បាយចិត្តដើរចេញពីបន្ទប់ប្រជុំ ដោយធ្វើឱ្យសមាជិកនិងអ្នកអង្កេតការណ៍រាប់រយនាក់ស្ថិតនៅក្នុងភាពស្រឡាំងកាំងយ៉ាងស្ងាត់ស្ងៀម។

## ៥_ទ័ពប្រទេសថៃទន្ទ្រានកម្ពុជា

*ថ្ងៃ១៥ ខែកក្កដា ឆ្នាំ២០០៨*

*ប្រទេសថៃប្រើលេសនៃការចុះបញ្ជីប្រាសាទព្រះវិហារដើម្បីទន្ទ្រានទឹកដីកម្ពុជា*

អម្លុងពេលមានការរំជើបរំជួលនៅទីក្រុងបាងកក គឺជាឱកាសដ៏ល្អបំផុតដែលថៃមានលេសអនុវត្តបំណងប្រាថ្នាដែលខ្លួនបានគ្រោងទុកតាំងពីយូរមកហើយ ដើម្បីអនុវត្តន៏មហិច្ឆតាយូរអង្វែងរបស់ខ្លួន ក្នុងវត្តុបំណងគូរខ្សែព្រំដែនឡើងវិញ។

នៅថ្ងៃ១៥ ខែកក្កដា ឆ្នាំ២០០៨ គឺទើបតែមួយសប្តាហ៍បន្ទាប់ពីការចុះប្រាសាទព្រះវិហារចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក កងកម្លាំងប្រដាប់អាវុធថៃបានចូលមកក្នុងប្រទេសកម្ពុជា មកជិត **ប្រាសាទព្រះវិហារ**។ កងកម្លាំងប្រដាប់អាវុធថៃបានប្រើលេសថាចូលមកចរចាសុំដោះលែងព្រះសង្ឃ ដូនជី និងអាចារ្យថៃ (ពុទ្ធសាសនិកក្លែងក្លាយ) ដែលបានចូលមកក្នុងតំបន់នេះដោយខុសច្បាប់។ តាមការពិតទាហានថៃបានទន្ទ្រានចូលមកក្នុងប្រទេសកម្ពុជាដើម្បីកាន់កាប់តំបន់ប្រាសាទព្រះវិហារនេះ។

ទាហានថៃបានចូលដល់វត្ត **កែវសិក្ខាគីរីស្វារៈ** ជាទីសក្ការៈបូជារបស់ប្រជាជនកម្ពុជា។ វត្តនេះមានចម្ងាយ៧០០ម ក្នុងអធិបតេយ្យកម្ពុជា ហើយមានចម្ងាយ៣០០ម ពី **ប្រាសាទព្រះវិហារ**។

កងទាហានថៃបានឆ្លងព្រំដែនកម្ពុជា ហើយចូលយ៉ាងជ្រៅក្នុងទឹកដីកម្ពុជា

កងទាហានថៃកាន់កាប់វត្តកែវសិក្ខាគីរីស្វារៈ និងប៉ុស្តិ៍រដ្ឋបាលកម្ពុជា (រូបភាព : ទីស្តីការគណៈរដ្ឋមន្ត្រី-រាជរដ្ឋាភិបាលកម្ពុជា)

បន្ទាប់ពីការលុកលុយលើកដំបូង កងទ័ពថៃបានបន្តបញ្ជូនទ័ពបន្ថែមទៀតមកកាន់តំបន់នោះ ដោយមានទាហានជាច្រើនរយនាក់បំពាក់ទៅដោយអាវុធយុទ្ធភណ្ឌ នៅតំបន់ជិត **ប្រាសាទព្រះវិហារ** និងជាច្រើនពាន់នាក់ទៀត ប្រដាប់ដោយកាំភ្លើងធំនិងកាំភ្លើងយន្ត នៅខាងម្ខាងព្រំដែន។ ថៃថែមទាំងបានឈ្លានពានដែនអាកាសដោយយន្តហោះចម្បាំងហោះចូលតំបន់ក្បែរព្រំដែន។

នៅថ្ងៃដដែលនៃការលុកលុយទន្ទ្រានដីគោក ប្រទេសថៃបានបង្ហាញយន្តហោះ ធុន F១៦ និងយន្តហោះចម្បាំងដទៃទៀត (រូបថត : យោធាថៃ, Wing I Korat)

ប្រទេសថៃបង្ហាញសាច់ដុំផ្នែកយោធា រួមទាំងរថក្រោះ និងកាំភ្លើងធ្លោងចម្ងាយឆ្ងាយ (រូបថត : យោធាថៃ)

ទាហានថៃតម្លើងកាំភ្លើងធំធុនធ្ងន់នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ (រូបថត : AFP)

បន្ទាប់ពីវត្តមានកងទ័ពថៃនៅជុំវិញ និងក្នុងវត្តកែវសិក្ខាគិរីស្វារៈ រដ្ឋាភិបាលថៃបានបោះបង់ចោលលេសពីមុនថា ខ្លួនចូលមកក្នុងវត្តនេះដើម្បីរំដោះជនអន្តោប្រវេសន្តជាតិថៃខុសច្បាប់។ ជាជំនួសវិញ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ សាម៉ាក់ ស៊ុនដារាវេជ Samak Sundaravej បានប្រកាសថាវត្តនោះស្ថិតនៅក្នុងដែនដីរបស់ព្រះរាជាណាចក្រថៃ។ តាមរយៈសារលិខិតមួយច្បាប់ជូនចំពោះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នាយករដ្ឋមន្ត្រីថៃអះអាងថា **"វត្តមាននៃវត្តនេះ និងសំណង់ផ្សេងៗទៀត ក៏ដូចជាវត្តមានអ្នកតាំងទីលំនៅ និងកងកម្លាំងកម្ពុជានៅក្នុងតំបន់នេះ គឺជាការរំលោភអធិបតេយ្យ និងបូរណភាពដែនដីរបស់ព្រះរាជាណាចក្រថៃជាបន្តបន្ទាប់"**[១]។

[១] លិខិតពីនាយករដ្ឋមន្ត្រី សាម៉ាក់ ស៊ុនដារ៉ាវេជ Samak Sundaravej ផ្ញើជូនសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃ ១៨ ខែកក្កដា ឆ្នាំ២០០៨

ក្នុងការឆ្លើយតប សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់ថា :

***[...យោងតាម "ផែនទីឧបសម្ព័ន្ធ I" ដែលប្រើប្រាស់ដោយតុលាការយុត្តិធម៌អន្តរជាតិ ហៅកាត់ថា (ICJ) នៅក្នុងឆ្នាំ ១៩៦២ វត្តកែវសិក្ខាគិរីស្វារៈ ស្ថិតនៅចម្ងាយប្រមាណ៧០០ម៉ែត្រក្នុងដែនដីកម្ពុជាយ៉ាងស្របច្បាប់ ។ "ផែនទីឧបសម្ព័ន្ធ I" ដែលបានប្រើប្រាស់ដោយតុលាការយុត្តិធម៌អន្តជាតិជាមូលដ្ឋានសម្រាប់ការកាត់សេចក្តីនៅ ក្នុងឆ្នាំ១៩៦២ ត្រូវបានគូរនៅក្នុងឆ្នាំ១៩០៨ ដែលជាលទ្ធផលនៃការងារកំណត់ព្រំដែននៃគណៈកម្មការកំណត់ព្រំដែនរវាងឥណ្ឌូចិន និងសៀមដែលបានបង្កើតឡើង អាស្រ័យអនុសញ្ញាឆ្នាំ១៩០៤ និង សន្ធិសញ្ញា ឆ្នាំ១៩០៧ រវាងបារាំង និងសៀម ហើយត្រូវបានយល់ព្រមដោយព្រះរាជាណាចក្រសៀមទៀតផង ។ នៅក្នុងការពិចារណារបស់ខ្លួន តុលាការយុត្តិធម៌អន្តរជាតិបានបង្ហាញឱ្យឃើញយ៉ាងច្បាស់អំពី សុពលភាពស្របច្បាប់នៃខ្សែព្រំដែន គឺមានដូចដែលបានបង្ហាញនៅក្នុង "ផែនទីឧបសម្ព័ន្ធ I" ]*** [២]

គឺជាការដែលគួរឱ្យកត់សម្គាល់ថា អ្វីដែលអតីតនាយករដ្ឋមន្ត្រីថៃអះអាងក្នុងសារលិខិតថា ជាការរំលោភបំពានទៅលើអធិបតេយ្យថៃ បានក្លាយជាប្រធានបទនៃការជំទាស់របស់ថៃអស់រយៈពេល ៤ឆ្នាំ ទៅហើយ ។ ក៏ប៉ុន្តែបើពិនិត្យលើកំណត់ត្រាឯកសារទូតដែលគាត់លើកឡើងជាបង្អែក គេមិនឃើញមានការអះអាងជាក់លាក់ណាមួយដែលថា អធិបតេយ្យនិងបូរណភាពដែនដីរបស់ថៃត្រូវបានរំលោភនោះឡើយ ។ ការជំទាស់របស់ថៃចាប់អារម្មណ៍ច្រើនទៅលើកត្តាជាក់ស្តែងដូចជា កំណើនប្រជាជន និងផលវិបាកមានសំរាមកាន់តែច្រើនឡើង ព្រមទាំងការបោះចោលសំរាមជាដើម ។ បញ្ហាដែលបានលើកឡើងមិនជាប់ទាក់ទងទៅនឹងបរិបទនៃការឈ្លានពានអធិបតេយ្យនោះទេ ។

គ្មានអ្វីគួរឱ្យងឿងឆ្ងល់ទេ បញ្ហាពាក់ព័ន្ធទៅលើការអះអាងថាជាទឹកដីរបស់ថៃនោះ រឿងនេះទើបតែលេចឡើងនៅក្នុងពេលថ្មីៗនេះតែប៉ុណ្ណោះ ចំណែកឯហេតុផលពិតប្រាកដនោះវិញ គឺមានទំនាក់ទំនងយ៉ាងច្រើនជាមួយបញ្ហាអស្ថិរភាពនយោបាយនៅក្នុងប្រទេសថៃ មិនខុសអំពីការមិនសប្បាយចិត្តចំពោះការសម្រេចរបស់តុលាការអន្តរជាតិ ឆ្នាំ១៩៦២ ស្តីអំពីអធិបតេយ្យ **ប្រាសាទព្រះវិហារ** នោះឡើយ ។ កំណត់ត្រាឯកសារការទូតរបស់ថៃមានគោលបំណងបង្កើតប្រវត្តិសាស្ត្រនៃជម្លោះព្រំដែនមួយ ដែលតាមការពិតទៅវិញ គឺមិនមានជម្លោះទាស់ទែងណាមួយតាំងពីច្រើនទសវត្សមកហើយ ។

[២] លិខិតពីសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ផ្ញើជូន នាយករដ្ឋមន្ត្រី សាម៉ាក់ ស៊ុនដារ៉ាវេជ Samak Sundaravej នៅថ្ងៃ ១៩ ខែកក្កដា ឆ្នាំ២០០៨

## ៦_ផលវិបាកនៃអរិភាពរបស់ថៃមកលើកម្ពុជា : ជម្លោះក្រោយការឈ្លានពានទឹកដី និង ការកាន់កាប់ខុសច្បាប់

ចាប់តាំងពីពេលដែលទ័ពថៃឆ្លងកាត់ខ្សែព្រំដែន ដែលជាខ្សែព្រំដែនអន្តរជាតិនោះមក ប្រទេសថៃបានប្រើវិធានការផ្សេងៗ ដើម្បីពង្រីកការត្រួតត្រាលើទឹកដីប្រទេសកម្ពុជា ដែលខ្លួនបានឈ្លានពានកាន់កាប់ដោយខុសច្បាប់។ វិធានការទាំងនោះ រួមមានការប្រើកម្លាំងយោធា និង មិនមែនកម្លាំងយោធា។

ដោយហេតុថា ទាហានថៃបានប៉ុនប៉ងជ្រៀតចូលកាន់តែជ្រៅទៅក្នុងទឹកដីកម្ពុជាតាមរយៈកងល្បាតរបស់ខ្លួន ម្លោះហើយកងល្បាតថៃមិនអាចចៀសផុតពីឧប្បត្តិហេតុដើរជាន់មីន ដោយពួកគេដើរឆ្លងកាត់ចំការមីន ដែលនៅសេសសល់តាំងពីសម័យខ្មែរក្រហមមក។ ទាហានកម្ពុជាជាម្ចាស់ស្រុក ដឹងច្បាស់ពីទីតាំងចំការមីនទាំងនោះ ហើយមិនបានទទួលរងគ្រោះថ្នាក់ដោយការដើរជាន់មីននោះទេ។ ចំណែកឯទាហានថៃវិញ ម្តងណាទាហានថៃផ្សងព្រេងដើរចូលចំការមីនក្នុងទឹកដីកម្ពុជា ដែលជាកំហុសរបស់ពួកគេសុទ្ធសាធ ទាហានថៃតែងតែបន្ទោសដល់ទាហានកម្ពុជាថា បានបង្កប់គ្រាប់មីនថ្មីៗទៀតវិញ ហើយឧប្បត្តិហេតុបែបនេះ ប្រាកដជានាំបណ្តាលឱ្យមានគ្រោះថ្នាក់ស្លាប់ ឬរបួសកាន់តែច្រើនឡើងមិនខាន ដែលជាលទ្ធផលនៃសកម្មភាពពង្រីកទឹកដីរបស់ថៃ។

ការប៉ុនប៉ងពង្រីកទឹកដីរបស់ថៃ បាននាំមកនូវការប្រយុទ្ធគ្នាយ៉ាងធ្ងន់ធ្ងរ។ នៅថ្ងៃ ១៥ ខែតុលា ឆ្នាំ២០០៨ មានការប្រយុទ្ធគ្នាមួយបានផ្ទុះឡើង រវាងទាហានកម្ពុជា និងទាហានថៃ។ ទន្ទឹមពេលប៉ុនប៉ងទម្លាក់កំហុសមកលើយុទ្ធជនកម្ពុជា ភាគីថៃក៏បានទទួលស្គាល់ថាទាហានថៃ **បានដើរល្បាត** តាមខ្សែព្រំដែន ដែលការណ៍នេះ បង្ហាញយ៉ាងជាក់ស្តែងពីបំណងឈ្លានពានរបស់ថៃ។




ថ្ងៃ១៥ ខែតុលា ឆ្នាំ២០០៨ វេលាម៉ោង ១៤:១៥ ទាហានថៃចាប់ផ្តើមបំផ្ទុះអាវុធមកលើកងទ័ពកម្ពុជា នៅពាកន្លែងផ្សេងគ្នា ដោយចូលយ៉ាងជ្រៅក្នុងទឹកដីកម្ពុជា។

តំបន់ទី១ : **វាលឥន្ទ្រី** ចម្ងាយប្រហែលជា១.១២០ម៉ែត្រ ភាគខាងត្បូងនៃព្រំដែនអន្តរជាតិរវាងប្រទេសកម្ពុជា និងប្រទេសថៃ។

តំបន់ទី២ : **ភ្នំទ្រព្យ** ចម្ងាយ១.៦០០ម៉ែត្រ ភាគខាងត្បូងនៃព្រំដែន អន្តរជាតិរវាងប្រទេសកម្ពុជា និងប្រទេសថៃ។

តំបន់ទី៣ : ក្នុងបរិវេណ **វត្តកែវសិក្ខាគីរីស្វារៈ** ចម្ងាយ៣០០ម៉ែត្រ ភាគខាងលិច នៃ **ប្រាសាទព្រះវិហារ** និងប្រហែលជា៧០០ម៉ែត្រ ពីព្រំដែនអន្តរជាតិ។

កាន់តែធ្ងន់ធ្ងរជាងនេះទៀត ការប្រយុទ្ធគ្នាមួយទៀតបានផ្ទុះឡើងនៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៩ ដោយថៃបានបាញ់គ្រាប់រ៉ុកកែត និងអាវុធធុនធ្ងន់ ធ្វើឱ្យខូចខាតដល់ប្រាសាទព្រះវិហារជាច្រើនកន្លែង ព្រមទាំងបំផ្លាញផ្សារមួយនៅក្បែរប្រាសាទទាំងស្រុង និងធ្វើឱ្យប៉ះពាល់ជីវភាពរបស់ប្រជាជនកម្ពុជាចំនួន៣១៩គ្រួសារដែលបានរស់នៅទីនោះតាំងពីយូរយារណាស់មកហើយ ។

ភូមិផ្សារបានឆេះ និង បំផ្លាញទាំងស្រុង ដោយគ្រាប់កាំភ្លើងធំរបស់កងទាហានថៃ (រូបថត : ទីស្តីការគណៈរដ្ឋមន្ត្រី-រាជរដ្ឋាភិបាលកម្ពុជា)

ប្រជាជនកម្ពុជា ៣១៩គ្រួសារ ត្រូវបានក្លាយជាទុគ៌តជនដោយអរិភាពរបស់កងទាហានថៃ (រូបថត : ទីស្តីការគណៈរដ្ឋមន្ត្រី-រាជរដ្ឋាភិបាលកម្ពុជា)

បន្ថែមពីលើទង្វើយោធានេះ ប្រទេសថៃក៏បានប្រកាសជាផ្លូវការថា នរណាក៏ដោយដែលធ្វើដំណើរទៅកាន់ប្រាសាទព្រះវិហារ ត្រូវតែមានការអនុញ្ញាតពីថៃដោយរាប់បញ្ចូលមិនត្រឹមតែមន្ត្រីរបស់កម្ពុជានោះទេ សូម្បីតែអ្នកជំនាញការអន្តរជាតិ បុគ្គលិកអង្គការយូណេស្កូ និងគណៈកម្មាធិការបេតិកភណ្ឌពិភពលោកដែលមានភារកិច្ចថែរក្សា **ប្រាសាទព្រះវិហារ** ក៏ត្រូវសុំការអនុញ្ញាតពីថៃដែរ ។ ការព្រមានបែបនេះ សរបញ្ជាក់ឱ្យឃើញពីការពង្រីកទឹកដីរបស់ថៃយ៉ាងសាហាវកាន់តែច្បាស់ថែមទៀតរហូតមកដល់ពេលនេះ ។

## ៧_អនាគតនៃប្រាសាទព្រះវិហារ

សកម្មភាពថ្មី១ដែលទើបបានប្រព្រឹត្តទៅដោយរាជរដ្ឋាភិបាលថៃ ក្នុងកិច្ចប្រជុំលើកទី៣៣របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោកនៅទីក្រុង សេវីល Seville ប្រទេសអេស្ប៉ាញ បង្ហាញថារាជរដ្ឋាភិបាលថៃនឹងមិនបោះបង់ចោលគំនិតទាមទារចង់បានទឹកដីកម្ពុជា ឬបំណងរុលត្បុលខ្លួនគេមកលើអធិបតេយ្យរបស់ប្រាសាទព្រះវិហាររបស់ខ្មែរសោះឡើយ។ មុនពេលមានកិច្ច ប្រជុំនៅប្រទេសអេស្ប៉ាញ ខែកក្កដា ឆ្នាំ២០០៩ ឥស្សរជនថៃរួមមាននាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងប្រធានគណៈប្រតិភូដែលត្រូវចូលរួមក្នុងអង្គប្រជុំបេតិកភណ្ឌពិភពលោក បាននិះគន់យ៉ាងខ្លាំងដល់អង្គការយូណេស្កូ និងគណៈកម្មាធិការបេតិកភណ្ឌពិភពលោក លើបញ្ហាចុះប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោកកាលពីឆ្នាំ២០០៨ និងបានប្រកាសនូវវត្ថុបំណងផ្សេង១ជាច្រើនរបស់រដ្ឋាភិបាលថៃនៅក្នុងអង្គប្រជុំ នាទីក្រុងសេវីល Seville នោះ។ ភាគីថៃចង់ឱ្យមានការពិនិត្យពិចារណាឡើងវិញនូវការសម្រេចនាទីក្រុងកេបិច ដែលបានចុះបញ្ជីប្រាសាទព្រះវិហារ។ ប្រទេសថៃក៏បានប្រកាសផងដែរថាថៃចង់បានការគ្រប់គ្រង រួមមួយលើប្រាសាទព្រះវិហារ ដែលជាគំនិតអាក្រក់មួយត្រូវបានកម្ពុជាជំទាស់នៅក្នុងកិច្ចប្រជុំកាលពីឆ្នាំមុន១។ បើមិនបានអញ្ចឹងទេ ភាគីថៃមានបំណងផ្សេងទៀតគឺភាគីថៃចង់ចុះបញ្ជីប្រាសាទ ព្រះវិហាររួមគ្នាជាមួយកម្ពុជា ឬដកប្រាសាទព្រះវិហារចេញពីបញ្ជីបេតិកភណ្ឌពិភពលោក។

សំណើរបស់ភាគីថៃមិនត្រូវបានអង្គប្រជុំទទួលស្គាល់ឡើយ។ គណៈប្រតិភូរបស់ថៃមិនត្រូវបានផ្តល់សិទ្ធិដើម្បីនិយាយនៅក្នុងអង្គប្រជុំនោះទេ។ យ៉ាងណាក៏ដោយ ក្រោយពេលត្រឡប់មកដល់ទីក្រុងបាងកកវិញ ភាគីថៃបានប្រកាសថា ពួកគេនឹងរៀបចំសម្រាប់កិច្ចប្រជុំនាឆ្នាំក្រោយរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក ដើម្បីសើរើបញ្ហាព្រះវិហារឡើងវិញ ហើយជំរុញឱ្យមានការចុះប្រាសាទព្រះវិហាររួមគ្នាជាមួយថៃនៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

បន្ថែមពីលើនេះទៀត បន្ទាប់ពីប្រទេសថៃ ត្រូវបានបោះឆ្នោតឱ្យចូលអង្គុយជាសមាជិកគណៈកម្មាធិការបេតិកភណ្ឌពិភពលោក សំរាប់អាណត្តិ៤ឆ្នាំ (២០០៩-២០១២) ដូចគ្នានិងកម្ពុជា ដែរនោះរាជរដ្ឋាភិបាលថៃបានប្រកាសរួចជាស្រេចថានឹងប្រើអាសនៈនេះ **ស្វែងរកពតិមាន** ដើម្បីរិតតែធ្វើឱ្យសមាជិកអនុសញ្ញាឆ្នាំ១៩៧២ កាន់តែបានយល់ច្បាស់អំពីការទាមទាររបស់ថៃ ក្នុងបញ្ហាប្រាសាទព្រះវិហារ ក្នុងគោលបំណងឱ្យបានទៅដល់ការចុះបញ្ជីរួម ឬការគ្រប់គ្រងរួមដែលភាគីកម្ពុជាបានទាត់ចោលប្រកបដោយជោគជ័យអស់រយៈវេលា ៣ឆ្នាំកន្លងទៅ គឺចាប់តាំងពីគ្រៃឆឺច ណូវែលហ្សេឡង់ (២០០៧) រហូតដល់ សេវីល អេស្ប៉ាញ (២០០៩) ឆ្លងតាម កេបិច កាណាដា (២០០៨)ដែលប្រាសាទព្រះវិហារត្រូវបានចុះបញ្ជីបេតិកភណ្ឌភិភពលោក។

ជាការពិតណាស់ ដោយរាជរដ្ឋាភិបាលថៃមិនបានទទួលជោគជ័យក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួន ដើម្បីកាន់កាប់ទឹកដីនិងត្រួតត្រាលើទីតាំងប្រាសាទព្រះវិហារ ដែលត្រូវបានតុលាការយុត្តិធម៌អន្តរជាតិសម្រេចរួចហើយនៅឆ្នាំ១៩៦២នោះ ថៃនៅតែបន្តគម្លើងសាច់ដុំប្រើកម្លាំងកងទ័ពរបស់ខ្លួន ព្រមទាំងបង្កើនយុទ្ធនាការទូត ដើម្បីឈានឆ្ពោះទៅរកផែនការ និងឧបាយកលអាស្រូវជួរជាតិផ្សេងទៀត។ ទោះជាយ៉ាងណាក៏ដោយ នេះជាជម្រើសដ៏គួរឱ្យខ្មាសអៀនរបស់ឥស្សរជនថៃ ពីព្រោះថា ដោយផ្អែកលើមូលដ្ឋានច្បាប់និងប្រវត្តិសាស្ត្រដ៏រឹងមាំ ព្រមទាំងភាពប្រុងប្រយ័ត្នដ៏ខ្ជាប់ខ្ជួន ប្រទេសកម្ពុជាអាចថៃរក្សាអធិបតេយ្យរបស់ខ្លួនលើប្រាសាទព្រះវិហារដ៏ពិសិដ្ឋនេះ ព្រមទាំងរក្សាការពារទឹកដីកម្ពុជា ក្នុងតំបន់ប្រាសាទព្រះវិហារបានទាំងស្រុង ។

# ឧបសម្ព័ន្ធ

## សម្រង់អនុសញ្ញា និងសន្ធិសញ្ញា

បកប្រែក្រៅផ្លូវការ ដោយ

វ៉ែន ឿន ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី

និងសហការី -លឹម សុគន្ធា មន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី

-កែវ ភក្តី មន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី

## ប្រទេសបារាំង និង ប្រទេសកម្ពុជា

~~~~~~~~~~

## សន្ធិសញ្ញាមិត្តភាព ពាណិជ្ជកម្ម និង អាណាព្យាបាលបារាំង រវាងប្រទេសបារាំង និងប្រទេសកម្ពុជា~~ ព្រមព្រៀងនៅទីក្រុងឧត្តុង្គ ថ្ងៃ ១០ ខែ សីហា ឆ្នាំ ១៨៦៣ (បណ្ដូរសច្ចាប័ន នៅទីក្រុងឧត្តុង្គ ថ្ងៃ ១៤ ខែ មេសា ឆ្នាំ ១៨៦៤)

ព្រះករុណាជាម្ចាស់លើត្បូង នៃព្រះរាជាណាចក្រកម្ពុជា និងទេសាភិបាលខេត្ត កូសាំងស៊ីន បានព្រមព្រៀងគ្នាដូចតទៅ:

**ប្រការ ១:** ព្រះចៅអធិរាជរបស់ប្រជាជនជាតិបារាំង បានព្រមព្រៀងផ្ដល់អាណាព្យាបាលដល់ព្រះមហាក្សត្រព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២:** ព្រះចៅអធិរាជរបស់ប្រជាជនជាតិបារាំង នឹងតែងតាំងបេសកជនតំណាង ឬកុងស៊ុលបារាំង នៅអមព្រះមហាក្សត្រខ្មែរ ដែលជាអ្នកទទួលបន្ទុក ធ្វើឱ្យមានការអនុវត្តន៍ដាច់ខាតនូវខ្លឹមសារនៃកិច្ចព្រមព្រៀងអាណាព្យាបាលនេះ។ បេសកជនតំណាង ឬកុងស៊ុល រូបនេះ ត្រូវឋិតនៅក្រោមអំណាចគ្រប់គ្រងរបស់ទេសាភិបាលខេត្ត កូសាំងស៊ីន។

ព្រះមហាក្សត្រខ្មែរ អាចនឹងតែងតាំងបេសកជនខ្មែរម្នាក់ នៅទីក្រុង សៃហ្គន -(ព្រៃនគរ)- ដើម្បីសម្រួលទំនាក់ទំនង ដោយចំពោះជាមួយនិងទេសាភិបាលខេត្ត កូសាំងស៊ីន។

